

# បារមីភាគ ២

(ភាគបញ្ចប់)

## ចំណុចបដិបត្តិនៃបារមី

### ចំណុចបដិបត្តិនៃទានបារមី

ការធ្វើនូវសេចក្តីអនុគ្រោះ ដល់សត្វទាំងឡាយ ប្រព្រឹត្តទៅដោយការលះបង់ នូវគ្រឿងឧបករណ៍ដើម្បីសេចក្តីសុខ លះបង់រាងកាយ និងជីវិតដើម្បីកម្ចាត់ភ័យ ព្រមទាំងការសម្តែងធម៌ប្រាប់អំពីការបដិបត្តិផ្សេងៗ ។

ក្នុងទានបារមីនោះ មានទាន ៣ យ៉ាង គឺ **អាមិសទាន ១ អភយទាន ១ និង ធម្មទាន ១** ។ ក្នុងទានទាំងនោះ មានដូចតទៅ :

**អាមិសទាន** វត្ថុដែលព្រះបរមពោធិសត្វ គួរឱ្យ មាន ២ យ៉ាង គឺ វត្ថុខាងក្នុង ១ និងវត្ថុខាងក្រៅ ១ ។



ក្នុង ២ យ៉ាងនោះ វត្ថុខាងក្រៅមាន ១០ យ៉ាង គឺបាយ ១ ទឹក ១ សំពត់ ១ យាន ១ ផ្កាឈើ ១ គ្រឿងក្រអូប ១ គ្រឿងលាប ១ ទីដេក ១ ទីអាស្រ័យ ១ និងប្រទីប ១ ។ ក្នុងបណ្តាវត្ថុមានបាយជាដើម គឺមានវត្ថុច្រើនយ៉ាង ដោយចំណែកនៃរបស់ដែលជាខាទនីយៈ និងភោជនីយាហារ ។ ម្យ៉ាងទៀត វត្ថុ ៦ យ៉ាង គឺរូបារម្មណ៍រហូតដល់ធម្មារម្មណ៍ ដែលជា « ឆទាន »។ ក្នុងបណ្តាវត្ថុមានរូបារម្មណ៍ជាដើមនោះ មានវត្ថុច្រើនយ៉ាង មានវត្ថុដែលមានពណ៌ខៀវជាដើម ។ ហើយម្យ៉ាងទៀត វត្ថុច្រើនយ៉ាងដែលជាគ្រឿងឧបករណ៍ និងជាគ្រឿងធ្វើឱ្យរីករាយចិត្ត ដូចជាកែវមណី មាស ប្រាក់ កែវមុក្តា កែវប្រពាល ស្រែ ចម្ការ សួនច្បារ ទាសា ទាសី គោ ក្របី ។ល។

ក្នុងវត្ថុទាំងនោះ ព្រះមហាបុរស កាលដែលនឹងឱ្យនូវវត្ថុខាងក្រៅ ក៏ដឹងដោយខ្លួនឯងថា នឹងឱ្យដល់បុគ្គលដែលមានសេចក្តីត្រូវការ សូម្បីតែមិនសូមក៏ឱ្យ មិនចាំបាច់និយាយដល់ការដែលគេសូមនោះឡើយ ។ មានរបស់ឱ្យ

ទើបឱ្យ បើមិនមានរបស់ឱ្យទេ រមែងមិនឱ្យឡើយ កាលមានទេយ្យធម៌ រមែងឱ្យនូវរបស់ដែលជាទីប្រាថ្នា ។ ម្យ៉ាងទៀត មិនឱ្យសស្ត្រាវុធ គ្រឿងញៀន គ្រឿងស្រវឹង និងថ្នាំពិសជាដើមឡើយ សូម្បីរបស់លេងដែលប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស និងដែលនាំមកនូវសេចក្ដីប្រមាទ ក៏មិនឱ្យដែរ ។ ម្យ៉ាងទៀត មិនឱ្យរបស់ដែលមិនជាទីសប្បាយដល់អ្នកជំងឺទេ គឺឱ្យតែរបស់ដែលជាទីសប្បាយប៉ុណ្ណោះដ៏សមគួរតាមប្រមាណ ។

ក្នុងនោះឯង បើគ្រហស្ថសូមក៏ឱ្យនូវរបស់ដ៏សមគួរដល់គ្រហស្ថ បើបព្វជិតសូមក៏ឱ្យរបស់សមគួរដល់បព្វជិត មិនឱ្យរបស់ដែលសៅហ្មង មិនមែនឱ្យដោយអាស្រ័យលាភសក្ការៈ សេចក្ដីសរសើរ និងមិនមែនឱ្យដោយអាស្រ័យការតបស្នងទេ ពោលគឺឱ្យដោយមិនប្រាថ្នាផលអ្វីឡើយ ក្រៅអំពីសម្មាសម្ពោធិញ្ញាណនោះ ។

ក្នុងនោះឯងទៀត ឱ្យដោយមិនរង្កៀសចំពោះអ្នកសូម មិនបោះឱ្យដោយការមើលងាយ ចំពោះយាចកដែល



មិនសង្រួមក្តី ឬសូម្បីដែលគេមានសេចក្តីក្រោធ ជេរ មករកក្តី។ ដោយពិត គឺមានចិត្តជ្រះថ្លា ហើយឱ្យដោយសេចក្តីអនុគ្រោះ និងឱ្យដោយសេចក្តីគោរពតែម្យ៉ាងប៉ុណ្ណោះ ។

មិនឱ្យក្នុងបំណងបោកបញ្ឆោត ដោយប្រការណាមួយ ឬបំណងនឹងទម្លាយប្រយោជន៍អ្នកដទៃឡើយ គឺមានតែឱ្យដោយចិត្តដែលឥតសៅហ្មងតែម្យ៉ាង ។ មិនឱ្យទានដោយប្រើពាក្យសម្តីគ្រោតគ្រាត មិនពាក់មុខយក្ស មិនពាក់មុខខ្មោច ប៉ុន្តែឱ្យដោយមុខមនុស្ស មុខទេវតា វាចាពីរោះគួរជាទីស្រឡាញ់ ។

លោភៈមានច្រើនក្នុងទេយ្យធម៌ណា ព្រោះការពេញចិត្តដ៏ក្រៃលែងក្តី ព្រោះសន្សំក្នុងសន្តានមកយូរហើយក្តី ព្រោះសេចក្តីប្រាថ្នាតាមសភាពធម្មតាក្តី ព្រះបរម-ពោធិសត្វដឹងហើយ ក៏កម្ចាត់បង់នូវលោភៈក្នុងទេយ្យធម៌នោះដោយរហ័ស ដោយការស្វែងរកយាចកដើម្បីឱ្យ។ល។ គប្បីជ្រាបនូវការបដិបត្តិក្នុងទានខាងក្រៅ ដោយប្រការដូច្នេះឯង ។

ចំណែកទានខាងក្នុង គប្បីជ្រាបដោយវត្ថុពីរយ៉ាង គឺអវយវៈ និងជីវិត ។ ដូចបុរសណាម្នាក់ ដែលបានលះបង់ខ្លួនដល់អ្នកដទៃ ព្រោះហេតុអាហារ និងគ្រឿងស្លៀកពាក់ជាដើម រមែងដល់នូវភាពជាអ្នកជឿស្តាប់ ព្រោះខ្លួនជាទាសៈ យ៉ាងណា ព្រះមហាបុរសក៏យ៉ាងនោះដែរ មានចិត្តប្រាសចាកអាមិស ព្រោះហេតុសម្មាសម្ពោធិញ្ញាណ ប្រាថ្នាប្រយោជន៍សុខដ៏ខ្ពង់ខ្ពស់ដល់សត្វទាំងឡាយ បំណងនឹងបំពេញនូវទានឧបបារមី ទានបរមត្ថបារមី ទើបលះបង់ខ្លួនដើម្បីអ្នកដទៃ រមែងដល់នូវភាពជាអ្នកជឿស្តាប់ ភាពជាអ្នកធ្វើតាមបំណងប្រាថ្នានៃអ្នកសូម ដោយមិនញាប់ញ័រ មិនរួញរា ប្រគល់អវយវៈតូចធំ មានដៃជើង និងភ្នែកជាដើម ឱ្យដល់អ្នកដែលត្រូវការនោះៗ មិនស្ទាក់ស្ទើរ មិនរារែក មិនតក់ស្លុត មានមុខស្រស់បស់ដូចជាការឱ្យនូវវត្ថុខាងក្រៅនោះដែរ ។

ការពិតគឺដូច្នោះឯង ព្រះមហាបុរស ញ៉ាំងសេចក្តីប្រាថ្នានៃយាចកទាំងនោះឱ្យសម្រេចដោយបរិបូណ៌ មាន



ការឱ្យបរិភោគតាមសប្បាយនូវបាយទឹកជាដើម ដោយប្រាថ្នាថា យើងឱ្យទានអស់ហើយ នឹងសម្រេចនូវសម្មា-សម្ពោធិញ្ញាណដោយការលះបង់នោះៗ យ៉ាងណា ការឱ្យវត្ថុខាងក្នុងក៏មានការលះបង់ប្រព្រឹត្តទៅ យ៉ាងនោះដែរ ។ គប្បីជ្រាបការបដិបត្តិក្នុងទាន ដែលព្រះមហាបុរសឱ្យរបស់ខាងក្នុង ដោយប្រការដូច្នេះឯង ។

ការឱ្យវត្ថុខាងក្នុង រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់យាចកតែប៉ុណ្ណោះ គឺព្រះមហាបុរសកាលដែលដឹងហើយ រមែងមិនឱ្យអត្តភាព ឬអវយវៈតូចធំរបស់ខ្លួនដល់មារ ឬដល់ទេវតាដែលជាបក្សពួករបស់មារឡើយ ព្រោះជាអ្នកមានបំណងនឹងបៀតបៀន ដោយព្រះមហាបុរសគិតថា សេចក្តីវិនាសចូរកុំគប្បីមានដល់មារ និងពួកមារទាំងនោះ ។

**អភយទាន** គប្បីជ្រាបដោយការរក្សាការពារនូវភ័យ កុំឱ្យប្រាកដដល់សត្វទាំងឡាយ មានភ័យកើតពីព្រះរាជា កើតពីចោរ កើតពីទឹក ភ្លើង សត្រូវ និងសត្វកាច

មានរាជសីហ៍ ខ្លា ដំរីជាដើម ។

**ធម្មទាន** ជាទានវិសេស បានដល់ការសម្ដែងធម៌មិនវិបរិតដល់បុគ្គលដែលមានចិត្តជ្រះថ្លា ព្រះមហាបុរសសម្ដែងចង្អុលបង្ហាញប្រាប់នូវប្រយោជន៍ដ៏សមគួរ នាំអ្នកដែលមិនទាន់ចូលដល់ព្រះពុទ្ធសាសនា ឱ្យបានចូលដល់ឯអ្នកដែលបានចូលដល់ហើយ ជួយឱ្យរីងរឹតតែចម្រើនរុងរឿងតទៅទៀត ប្រព្រឹត្តទៅក្នុងប្រយោជន៍បច្ចុប្បន្នប្រយោជន៍បរលោក និងប្រយោជន៍ដ៏ក្រៃលែង គឺបានដល់ព្រះនិព្វាន ។

ក្នុងការសម្ដែងធម៌នោះ គប្បីជ្រាបន័យដោយសង្ខេបដូចនេះគឺ ទានកថា សីលកថា សគ្គកថា (ពោលពីឋានសួគ៌ ) កាមាទីនវកថា (ពោលពីទុក្ខទោស សេចក្ដីសៅហ្មងរបស់កាម ) នេក្ខម្មានិសង្សកថា (ពោលពីអានិ-សង្សក្នុងការចេញចាកកាម ) ។ ចំណែកដោយពិស្ដារគប្បីជ្រាបអំពីការប្រតិស្ឋាន និងការធ្វើឱ្យផ្លូវផង់ ក្នុងធម៌នោះៗ តាមសមគួរ ដោយអំណាចនៃការប្រកាសគុណ



របស់ធម៌នោះៗ ដល់បុគ្គលដែលមានចិត្តបង្អោនទៅហើយក្នុងសាវកពោធិញ្ញាណ គឺការចូលដល់សរណៈ ការសង្រួមក្នុងសីល ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការស្គាល់ប្រមាណក្នុងការបរិភោគ ការប្រកបសេចក្ដីព្យាយាមរឿយៗក្នុងការភ្ញាក់រលឹក ការមាននូវព្រះសទ្ធម្ម ៧ (សទ្ធា ហិរិ ឱត្តប្បៈ ពាហុសច្ចៈ វីរិយៈ សតិ បញ្ញា ) ការប្រកបសមថៈ ការចម្រើនវិបស្សនា និងបដិបទាដ៏ហ្មត់ចត់ តាំងចិត្តខ្ជាប់ខ្ជួន ចាប់យកនូវការពិតដ៏ត្រឹមត្រូវ ប្រព្រឹត្តទៅដើម្បីវិជ្ជា ៣ អភិញ្ញា ៦ បដិសម្ភិទា ៤ សាវក-ពោធិញ្ញាណ ។ ព្រះមហាបុរស ប្រកាសសម្ដែងអំពីអានុភាពដ៏ក្រៃលែងនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ គឺប្រកាសអំពីបារមី មានទានបារមីជាដើម តាមសមគួរដល់អធ្យាស្រ័យនៃសត្វទាំងឡាយ ដែលបង្អោនចិត្តទៅក្នុងញាណទាំងពីរ គឺបច្ចេកពោធិញ្ញាណ និងសម្មាសម្ពោ-ធិញ្ញាណ ។ ព្រះមហាបុរសរមែង ឱ្យនូវធម្មទានដល់សត្វទាំងឡាយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះមហាបុរស កាលឱ្យអាមិសទាន ដល់សត្វទាំងឡាយ រមែងឱ្យបាយដោយតាំងចិត្តថា យើង គប្បីញ៉ាំងសម្បត្តិ មានអាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ ជាដើម និងបានញ៉ាំងសម្បត្តិ គឺផលដ៏លើសគួរជាទីរីករាយ ឱ្យសម្រេចដល់សត្វទាំងឡាយ ដោយទាននេះ ( ដល់ពេល ព្រះអង្គបានត្រាស់ ព្រះអង្គនឹងឱ្យអ្វីៗ ទាំងនោះ ) ។

ឱ្យទឹក ដើម្បីរម្ងាប់នូវការស្រេក គឺកិលេសកាម របស់សត្វទាំងឡាយ ។

ឱ្យសំពត់ ដើម្បីឱ្យពណ៌សម្បុរល្អ និងដើម្បីឱ្យ សម្រេចនូវគ្រឿងប្រដាប់គឺហិរិ ឱត្តប្បៈ ។

ឱ្យយាន ដើម្បីឱ្យសម្រេចនូវឥទ្ធិវិធិ គឺការសម្តែង ឫទ្ធិបាន និងនិព្វានសុខ ។

ឱ្យគ្រឿងក្រអូប ដើម្បីឱ្យសម្រេចនូវការដែលមាន ក្លិនក្រអូប គឺសីល ។

ឱ្យផ្កាឈើ និងគ្រឿងលាប ដើម្បីឱ្យសម្រេចនូវ សេចក្តីល្អ ដោយពុទ្ធគុណ ។



ឱ្យអាសនៈ ដើម្បីឱ្យសម្រេចនូវអាសនៈនាពោធិ- មណ្ឌល ។

ឱ្យទីដេក ដើម្បីឱ្យសម្រេចនូវតថាគតសេយ្យា គឺ បន្ទំព្រះតថាគត ។

ឱ្យទីសំណាក់ ដើម្បីឱ្យសម្រេចនូវភាពជាសមណៈ។

ឱ្យប្រទីប ដើម្បីឱ្យបាននូវចក្ខុទាំង ៥ ។

ឱ្យរូបជាទាន ដើម្បីឱ្យសម្រេចនូវរស្មីចេញចាកអំពី ព្រះវរកាយ ។

ឱ្យសំឡេងជាទាន ដើម្បីឱ្យសម្រេចនូវសំឡេងដូច សំឡេងព្រហ្ម ។

ឱ្យរសជាទាន[១] ដើម្បីជាទីស្រឡាញ់នៃសត្វលោក ទាំងពួង ។

ឱ្យផោដ្ឋព្វៈជាទាន ដើម្បីសម្រេចនូវភាពជាពុទ្ធ សុខុមាល គឺសេចក្តីសុខដ៏ល្អិតសុខុម សុខុមាលជាតិនៃព្រះ សម្មាសម្ពុទ្ធ ។

---

១.ឱ្យក្លិនជាទាន មានខាងដើមរួចហើយ ។

ឱ្យភេសជ្ជៈជាទាន ដើម្បីការមិនចាស់ មិនឈឺ មិនស្លាប់ គឺព្រះនិព្វាន ។

ឱ្យភាពជាអ្នកជា ជាឥស្សរៈដល់ទាសៈទាំងឡាយ ដើម្បីរួចរដោះពីទាសៈរបស់កិលេស ។

ឱ្យការត្រេកអរក្នុងរបស់លេង ដែលមិនមានទោស ជាទាន ដើម្បីសេចក្តីត្រេកអរក្នុងព្រះសទ្ធម្ម ។

ឱ្យបុត្រជាទាន ដើម្បីនាំសត្វទាំងអស់ចេញចាក សង្សារទុក្ខ ដែលសត្វលោកទាំងអស់ឋិតក្នុងភាពជាបុត្រ របស់ព្រះអង្គ មានជាតិជាព្រះអរិយៈ ។

ឱ្យភរិយាជាទាន ដើម្បីដល់នូវភាពជាធំក្នុងលោក ហើយចម្លងសត្វលោក ។

ឱ្យមាសប្រាក់កែវមណី កែវមុក្តា កែវប្រពាល ជាដើមជាទាន ដើម្បីភាពសម្បូណ៌ដោយលក្ខណៈ គឺ មហាបុរិសលក្ខណៈ ។

ឱ្យគ្រឿងប្រដាប់បែបផ្សេងៗជាទាន ដើម្បីភាព សម្បូណ៌នៃអនុព្យញ្ជនៈ គឺលក្ខណៈល្អិតល្អក្នុងព្រះវរកាយ។



ឱ្យឃ្លាំងសម្បត្តិជាទាន ដើម្បីសម្រេចនូវព្រះ-សទ្ធម្ម ។

ឱ្យរាជសម្បត្តិជាទាន ដើម្បីភាពជាព្រះធម្មរាជ ។

ឱ្យសួនច្បារចម្ការស្រះ និងព្រៃឈើជាទាន ដើម្បី ភាពសម្បូណ៌នៃឈានជាដើម ។

ឱ្យជើងជាទាន ដើម្បីឈានទៅកាន់ពោធិមណ្ឌល ដ៏មានពន្លឺរស្មី ដោយព្រះបាទដែលមានស្នាមចក្រ ។

ឱ្យដៃជាទាន ដើម្បីឱ្យដៃគឺព្រះសទ្ធម្មដល់សត្វទាំង-ឡាយ ជាប្រយោជន៍សម្រាប់ហែលឆ្លងអន្លង់ឱឃៈ ។

ឱ្យត្រចៀកនិងច្រមុះជាទាន ដើម្បីបាននូវឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើម ។

ឱ្យចក្ខុជាទាន ដើម្បីសមន្តចក្ខុ គឺចក្ខុដែលឃើញ ដោយជុំវិញ បានដល់សព្វញ្ញុតញ្ញាណ ។

ឱ្យសាច់ និងឈាមជាទាន ដោយសង្ឃឹមថា នឹងនាំ ប្រយោជន៍សុខមកឱ្យដល់សព្វសត្វរហូតអស់កាលទាំងពួង ក្នុងការឃើញ ការស្តាប់ ការរលឹកដល់ និងការបម្រើ

ជាដើមចំពោះព្រះអង្គជាព្រះសម្មាសម្ពុទ្ធ ព្រមទាំងព្រះវរកាយរបស់ព្រះអង្គ គប្បីជាកាយដែលសត្វលោកទាំងពួងបានចូលទៅអាស្រ័យដើម្បីប្រយោជន៍ដ៏ឧត្តម ។

ឱ្យអវយវៈដ៏ខ្ពង់ខ្ពស់ជាទីបំផុត គឺសីសៈជាទានដោយសង្ឃឹមថា យើងនឹងគប្បីជាបុគ្គលខ្ពង់ខ្ពស់ប្រសើរបំផុត និងជាចម្បងលើលោកទាំងពួង ។

ព្រះមហាបុរស កាលឱ្យដូចពោលមកហើយនោះ មិនឱ្យដើម្បីស្វែងរកកំហុសរបស់អ្នកដទៃ មិនឱ្យដើម្បីបៀតបៀនអ្នកដទៃដោយប្រការអ្វីមួយ មិនឱ្យព្រោះខ្លាចព្រោះខ្មាសគេ និងមិនក្រោធជាមួយទក្ខិណេយ្យបុគ្គលឡើយ ។

ព្រះមហាបុរស កាលមាននូវរបស់ប្រណីត មិនឱ្យរបស់សៅហ្មង ។ មិនឱ្យដោយការលើកតម្កើងខ្លួន បង្អាប់បង្អោនអ្នកដទៃ មិនប្រាថ្នាផលក្រៅអំពីភាពជាព្រះពុទ្ធ និងមិនខ្ពើមយាចកឡើយ ។ ដោយពិត ព្រះមហាបុរសមានតែការឱ្យទានដោយគោរព ឱ្យដោយដៃរបស់ខ្លួន ឱ្យ



តាមកាល ឱ្យដោយចិត្តត្រេកអរក្នុងកាលទាំង ៣ កាលឱ្យហើយមិនក្តៅក្រហាយស្តាយក្រោយ ។

ព្រះមហាបុរស បង្អោននូវទានសម្បទា តាមដែលបានពោលហើយនេះទាំងអស់ ដើម្បីប្រយោជន៍សុខដល់សត្វលោកទាំងអស់ ម្យ៉ាងទៀត បង្អោននូវទានសម្បទាដើម្បីសម្មាសម្ពោធិញ្ញាណរបស់ខ្លួន ដើម្បីវិមុត្តិមិនកម្រើកដើម្បីឆន្ទៈ វីរិយៈ សមាធិ បដិភាណ ញាណ និងវិមុត្តិដែលមិនចេះសាបសូន្យ ។

ព្រះមហាសត្វ បដិបត្តិទានបារមីនេះ មានការប្រាកដនូវអនិច្ចសញ្ញាក្នុងជីវិត ក្នុងភោគៈទាំងឡាយ ក៏ដូចគ្នា ហើយមាននូវមហាករុណាក្នុងសត្វទាំងឡាយជានិច្ចនាំយកនូវសម្បត្តិទាំងអស់ព្រមទាំងខ្លួនឯង ចេញចាកអំពីផ្ទះ ដូចចេញចាកអំពីផ្ទះដែលត្រូវភ្លើងឆេះ មិនឱ្យមានអ្វីសល់ គឺមានការបរិច្ចាគលះបង់ទាំងអស់ ។ នេះជាលំដាប់នៃការបដិបត្តិទានបារមី ។

## ចំណុចបដិបត្តិនៃសីលបារមី

ព្រះមហាបុរស មានបំណងនឹងតាក់តែងនូវសត្វទាំងឡាយដោយគ្រឿងប្រដាប់ គឺសីលរបស់ព្រះសព្វញ្ញូ គប្បីជម្រះសីលរបស់ខ្លួនតាំងពីខាងដើមជាមុនសិន ។

សីលរមែងបរិសុទ្ធដោយអាការ ៤ យ៉ាង គឺបរិសុទ្ធដោយអជ្ឈាស្រ័យ ១ ដោយការសមាទាន ១ ដោយការមិនប្រព្រឹត្តកន្លង ១ និងដោយការធ្វើឱ្យជាប្រក្រតីឡើងវិញ កាលដែលមានការប្រព្រឹត្តកន្លងហើយនោះ ១ ។

ពិតណាស់ មនុស្សខ្លះមានខ្លួនជាធំ ព្រោះអជ្ឈាស្រ័យបរិសុទ្ធ ខ្មាសខ្ពើមបាប ញុំាងហិរិឱ្យប្រាកដនៅខាងក្នុង ហើយមានសមាចារបរិសុទ្ធដោយប្រពៃ ។ មនុស្សខ្លះមានការសមាទាន យកលោកជាធំ ខ្លាចផលរបស់បាប ញុំាងឱត្តប្បៈឱ្យប្រាកដ ជាអ្នកមាននូវសមាចារបរិសុទ្ធដោយល្អ ដោយប្រការដូច្នេះ ។ មនុស្សទាំងនោះ រមែងតាំងនៅក្នុងសីល ព្រោះមិនប្រព្រឹត្តកន្លងសូម្បីទាំងពីរ



យ៉ាង ក៏ប៉ុន្តែថា ពេលខ្លះ ព្រោះមានការវង្វេង សីលក៏រមែងដាច់ទៅជាដើម ឯការធ្វើសីលដែលដាច់ទៅនោះឱ្យជាប្រក្រតីដោយឆាប់រហ័ស ដើម្បីសេចក្ដីដល់ព្រមនៃហិរិឱត្តប្បៈតាមដែលពោលហើយនោះឯង ។

សីលមាន ២ យ៉ាង គឺ **វារិត្តសីល** ១ **ចារិត្តសីល** ១។

សីល ២ យ៉ាងនោះ គប្បីជ្រាបលំដាប់នៃការបដិបត្តិក្នុង **វារិត្តសីល** របស់ព្រះបរមពោធិសត្វដូចតទៅនេះ :

ព្រះមហាបុរស ជាអ្នកមានចិត្តអាណិតក្នុងសព្វសត្វ សូម្បីតែក្នុងការយល់សប្តិក៏មិនគប្បីកើតការអាឃាតឡើយ ។ ឃើញរបស់ទ្រព្យអ្នកដទៃដូចឃើញពស់ពិស មិនចាប់កាន់យកដោយអាការលួចឡើយ ព្រោះមានតែការត្រេកអរក្នុងការជួយអ្នកដទៃ ។ ប្រសិនបើជាបព្វជិត ក៏ជាបុគ្គលប្រព្រឹត្តឆ្ងាយចាកអព្រហ្មចរិយៈ និងប្រាសចាកនូវមេថុនសំយោគ ៧ យ៉ាង[១] មិនចាំបាច់ពោលដល់រឿងប្រព្រឹត្តខុសក្នុងបុត្រភរិយារបស់អ្នកដទៃឡើយ តែបើជា

---

១-មេថុនសំយោគ ៧ យ៉ាងមានក្នុងបិដកលេខ ៤៧ ទំព័រ ១០១ ។

គ្រហស្ថ សូម្បីចិត្តលាមក ក៏មិនឱ្យកើតឡើងក្នុងភរិយារបស់អ្នកដទៃគ្រប់កាល ។ ពេលនិយាយ ក៏និយាយពាក្យល្មមប្រមាណ ជាពាក្យពិត មានប្រយោជន៍ ចម្រើនបុណ្យចម្រើនចិត្ត គួរជាទីពេញចិត្ត និងពោលធម៌តាមកាល ។ មិនលោភ មិនព្យាបាទ មិនឃើញខុស ប្រកបដោយកម្មស្សកតញ្ញាណ (បញ្ញាឃើញសត្វលោកប្រព្រឹត្តទៅតាមកម្ម ឃើញហេតុឃើញផលក្នុងជីវិត ) មានសទ្ធាមាំទាំក្នុងការបដិបត្តិដោយប្រពៃ មានមេត្តាករុណាក្នុងទីទាំងពួង ។

កាលព្រះមហាបុរស វៀរចាកនូវអកុសលកម្មបថដែលជាផ្លូវនៃអបាយភូមិ ៤ និងវដ្តទុក្ខហើយ ព្រះមហាបុរសក៏រមែងតាំងនៅក្នុងកុសលកម្មបថ ដែលជាផ្លូវនៃឋានសួគ៌ និងព្រះនិព្វាន ។

សេចក្តីប្រាថ្នារបស់ព្រះមហាបុរស ចូលទៅប្រកបប្រយោជន៍សុខ ដល់សត្វទាំងឡាយតាមប្រាថ្នា រមែងសម្រេចទាន់ពេល ព្រោះជាបុគ្គលមានអធ្យាស្រ័យបរិសុទ្ធ និងសម្បូណ៌ដោយបារមី ។



**ព្រះមហាបុរស** រមែងឱ្យនូវអភយទានដល់សព្វសត្វ **ដោយមិនប្រព្រឹត្តបៀតបៀន** បានញ៉ាំងមេត្តាភាវនា ឱ្យបរិបូណ៌ដោយមិនលំបាក រមែងសម្រេចនូវអានិសង្សមេត្តា ១១ ប្រការ[១] មានអាពាធតិច មិនឈឺចាប់ មានអាយុវែង មានសេចក្តីសុខច្រើន រមែងចូលដល់លក្ខណៈវិសេស និងកាត់វាសនាដែលជាទោសៈចេញបាន ។

**ព្រោះមិនប្រព្រឹត្តចោរកម្ម** ទើបបាននូវភោគសម្បត្តិដែលមិនទូទៅដល់ចោរជាដើម អ្នកដទៃមិនរង្កៀស ជាទីស្រឡាញ់ ជាទីពេញចិត្ត និងជាទីគួរគប់រកនៃអ្នកដទៃ មានចិត្តមិនជាប់ជំពាក់នឹងសម្បត្តិ ដែលមិនមែនជារបស់ខ្លួន ពេញចិត្តនឹងបរិច្ចាគ កាត់វាសនាដែលជាលោភៈចេញបាន ។

**ព្រោះមិនប្រព្រឹត្តខុសក្នុងព្រហ្មចរិយធម៌** (ការប្រព្រឹត្តធម៌ដ៏ប្រសើរ គឺ ប្រព្រឹត្តវៀរចាកកាមទាំងឡាយតាមសិក្ខាបទ ) ទើបជាបុគ្គលមិនឡេះឡោះ មានកាយនិងចិត្ត

---

១-អានិសង្សមេត្តាមាន ១១ ប្រការ ក្នុងបិដកលេខ ៥១ ទំព័រ ២៩៧ ។

ស្ងប់រម្ងាប់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនជាទីរង្កៀសនៃសត្វទាំងឡាយ កិត្តិស័ព្ទដ៏ប្រសើរល្បីខ្ចរខ្ចាយ មិនមានចិត្តជាប់ជំពាក់ក្នុងមាតុគ្រាមទាំងឡាយ មានអធ្យាស្រ័យមិនលោភ ច្រើនទៅដោយនេក្ខម្មៈ រមែងបាននូវលក្ខណៈវិសេស និងកាត់នូវវាសនាដែលជាលោភៈចេញបាន ។

**ព្រោះមិននិយាយកុហក** ទើបជាប្រមាណរបស់សត្វទាំងឡាយ ជាទីជឿទុកចិត្តបាន មានពាក្យសម្តី ដែលគួរកាន់យក ជាទីស្រឡាញ់ ជាទីពេញចិត្តនៃពួកទេវតា មានមាត់ក្រអូប រក្សាកាយសមាចារ វចីសមាចារ រមែងបាននូវលក្ខណៈវិសេស និងកាត់នូវវាសនាដែលជាកិលេសចេញបាន ។

**ព្រោះមិននិយាយញុះញង់** ទើបមានរូបកាយស្អាតល្អពេញលក្ខណៈ មានបរិវារមិនបែកបាក់គ្នា សូម្បីដោយសេចក្តីព្យាយាមរបស់អ្នកដទៃ មានសំឡេងមិនបែកក្នុងការសម្តែងនូវព្រះធម៌ មានចិត្តមាំទាំ ជាទីស្រឡាញ់របស់សត្វទាំងឡាយ និងច្រើនដោយការមិនសៅហ្មង ។



**ព្រោះមិននិយាយទ្រគោះបោះបោក** ទើបជាទីស្រឡាញ់ ជាទីពេញចិត្តរបស់សត្វទាំងឡាយ មានប្រក្រតីនៅជាសុខ និយាយពីរោះ គួរលើកតម្កើង និងសំឡេងប្រកបដោយអង្គ ៨ រមែងកើតឡើង [១] ។

**ព្រោះមិននិយាយរោយរាយ** ទើបជាទីស្រឡាញ់ ជាទីពេញចិត្ត គួរគោរព គួរលើកតម្កើងរបស់សត្វទាំងឡាយ មានពាក្យសម្តីគួរជឿបាន និយាយល្មមប្រមាណ មានយសស័ក្តិ និងមានអានុភាពច្រើន ឆ្លាតក្នុងការកែបញ្ហាដោយបដិភាណ មានប្រាជ្ញារហ័សឆ្លាតឈ្លាសក្នុងការឆ្លើយតបសំនួរ និង អាចជួយដោះស្រាយបញ្ហាទុក្ខលំបាកសន្ទឹកសន្ធាប់របស់សត្វទាំងឡាយបាន ។

**ព្រោះជាអ្នកមិនលោភ** ទើបបានលាភដែលត្រូវការបានភោគៈជាទីពេញចិត្តសព្វគ្រប់ប្រការ ជាទីព្រមទទួល

---

១-ក្នុងបិដកលេខ ១៧ ទំព័រ ៨៥ សំឡេងប្រកបដោយអង្គ ៨ គឺ សំឡេងក្បោះក្បាយ ១ សំឡេងងាយយល់ ១ សំឡេងទន់ពីរោះ ១ សំឡេងគួរស្តាប់ ១ សំឡេងគ្រលួច ១ សំឡេងមិនគ្រាវ ១ សំឡេងក្រអួនតាំងពីផ្ចិតឡើងទៅ ១ សំឡេងរំពងដូចផ្គរលាន់ ១ ។

នៃក្សត្រមហាសាលជាដើម សត្រូវគ្របសង្កត់មិនបាន មិនដល់នូវភាពជាអ្នកមានឥន្ទ្រិយពិការ និងជាបុគ្គលរកអ្នកណាប្រៀបពុំបាន ។

**ព្រោះមិនព្យាបាទ** ទើបជាបុគ្គលដែលគេគួរសម្លឹងមើល គួរស្រឡាញ់ ជាទីលើកតម្កើងនៃសត្វទាំងឡាយ ជាទីជ្រះថ្លានៃអ្នកដទៃ ព្រោះជាអ្នកមានអធ្យាស្រ័យដ៏ក្រៃលែង ក្នុងប្រយោជន៍របស់អ្នកដទៃ ជាអ្នកមានសភាពមិនសៅហ្មង រស់នៅដោយមេត្តា ជាអ្នកមានយសស័ក្តិ និងមាននូវអានុភាពច្រើន ។

**ព្រោះជាអ្នកមិនយល់ឃើញខុស** ទើបជាអ្នកមានមិត្តសម្លាញ់ល្អ សូម្បីនឹងត្រូវកាត់សីសៈ ក៏មិនធ្វើកម្មអាក្រក់ ជាអ្នកមិនជឿមង្គលភ្ញាក់ផ្អើល ព្រោះបានដឹងច្បាស់ថា សត្វមានកម្មជារបស់ខ្លួន មានសទ្ធាតាំងមាំក្នុងព្រះសទ្ធម្ម ជឿការត្រាស់ដឹងរបស់ព្រះតថាគត មិនត្រេកអរក្នុងលទ្ធិដទៃ ដូចរាជហង្សមិនត្រេកអរក្នុងទីស្មោកគ្រោក ដូច្នោះឯង ។ ជាអ្នកឆ្លាតក្នុងការកំណត់ដឹងនូវត្រៃលក្ខណ៍ និងជា



អ្នកសម្រេចបាននូវអនាវរណញ្ញាណក្នុងទីបំផុត ។ បើមិនទាន់បានសម្រេចនូវពោធិញ្ញាណដរាបណា ដរាបនោះនឹងជាបុគ្គលខ្ពង់ខ្ពស់ក្នុងពពួកជននោះៗ និងដល់នូវសម្បត្តិដ៏យ៉ាងច្រើនសន្ធឹកសន្ធាប់ ។

សីល ជាទីតាំងនៃសម្បត្តិទាំងពួង ជាដែនកើតនៃព្រះពុទ្ធគុណ ជាចរណៈ ជាប្រមុខនៃពុទ្ធការកធម៌ ទាំង-ឡាយ...កាលបើយល់ចូលចិត្តដូច្នេះហើយ គប្បីជាអ្នកមិនប្រមាទក្នុងការសង្រួមកាយវាចា មិនប្រមាទក្នុងការអប់រំឥន្ទ្រិយ មិនប្រមាទក្នុងសេចក្តីបរិសុទ្ធនៃអាជីវៈ និងគប្បីជាអ្នកមិនប្រមាទក្នុងការពិចារណាបច្ច័យទាំងឡាយ ។

ដោយកម្លាំងនៃសតិសម្បជញ្ញៈកំណត់លាភសក្ការៈ និងសេចក្តីសរសើរ ដូចសត្រូវនៅចំពោះមុខ ហើយគប្បីញ៉ាំងសីលឱ្យដល់ព្រម ។ នេះជាលំដាប់នៃការបដិបត្តិក្នុងវារិត្តសីល ។

**ចំណែកការបដិបត្តិក្នុងចារិត្តសីល** គប្បីជ្រាបយ៉ាងនេះគឺ :

-ព្រះបរមពោធិសត្វ ធ្វើនូវអភិវាទ រាក់ទាក់ក្រោក ទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ដល់កល្យាណមិត្តដែលតាំងនៅក្នុងឋានៈជាគ្រូរហូតគ្រប់ពេលវេលា ធ្វើការទំនុកបម្រុងនូវកល្យាណមិត្តនោះក៏គ្រប់ពេលវេលាដែរ ។

-ស្តាប់បទសុភាសិតហើយធ្វើសាធុការ ។

-ពណ៌នាគុណនៃអ្នកមាននូវគុណធម៌ ។

-អត់ធន់ ចំពោះការដែលអ្នកដទៃបានធ្វើនូវសេចក្តីវិនាសឱ្យដល់ខ្លួន យ៉ាងណាមួយ ។

-រលឹកដល់អ្នកដែលធ្វើនូវឧបការៈ ។

-អនុមោទនាបុណ្យ ។

-បង្អោនបុណ្យបារមីដើម្បីសម្មាសម្ពោធិញ្ញាណ ។

-មានជីវិត ឋិតនៅក្នុងសេចក្តីមិនប្រមាទចំពោះកុសលធម៌ទាំងឡាយគ្រប់ពេល ។

-កាលបើមានទោស ឃើញនូវទោសថាជាទោស ហើយ ក៏ប្រាប់ដល់សហធម្មិក គឺអ្នកប្រព្រឹត្តធម៌ជាមួយគ្នាទៅតាមសេចក្តីពិត និងការបំពេញ នូវសម្មាបដិបត្តិឱ្យ



ក្រៃលែងឡើងដោយប្រពៃ ។

-ពេលដែលគួរធ្វើនូវអ្វីដែលមានប្រយោជន៍សមគួរដល់សត្វទាំងឡាយ ក៏ជាអ្នកមានសេចក្តីព្យាយាម មិនខ្ជិលច្រអូស ។

-កាលទុក្ខមានការឈឺនូវជំងឺជាដើម កើតឡើងដល់សត្វទាំងឡាយ ក៏ជាអ្នកចាត់ការជួយតាមកម្លាំងដែលអាចប្រព្រឹត្តទៅបាន ។

-កាលសត្វទាំងឡាយ ធ្លាក់ចូលដល់សេចក្តីវិនាស មានវិនាសញាតិ និងសម្បត្តិជាដើម ក៏ជួយសម្រាលនូវសេចក្តីសោកឱ្យដល់គេ ។

នៅមានទៀត គឺជាអ្នកតាំងនៅក្នុងសភាពជាអ្នកជួយគេ ឃុំគ្រងនូវបុគ្គលដែលគួរឃុំគ្រងដោយត្រឹមត្រូវទៅតាមធម៌ ដើម្បីឱ្យគេបានរួចផុតពីបាបអកុសល ហើយតាំងនៅក្នុងបុណ្យកុសល។ លើកតម្កើងប្រកបដោយធម៌។

កម្មណាដែលធ្វើបានដោយលំបាកដ៏ក្រៃលែង និងធំធេងជាទីបំផុត មានអានុភាពជាអចិន្តេយ្យ ដែលនាំ

ប្រយោជន៍សុខមកឱ្យដល់សត្វទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ ដែលព្រះបរមពោធិសត្វអំពីមុនៗបានប្រព្រឹត្តហើយ ។ ពោធិសម្ភាររបស់ព្រះបរមពោធិសត្វទាំងនោះ បានដល់នូវភាពចាស់ក្លាដោយប្រពៃដោយកម្មទាំងឡាយណា បានស្តាប់នូវកម្មទាំងឡាយនោះហើយ មិនតក់ស្លុត បានគិតថា «មហាបុរសទាំងនោះក៏ជាមនុស្សដូចគ្នាដែរ មានអត្តភាពបានអប់រំដើម្បីភាពបរិបូណ៌នៃការសិក្សាតាមលំដាប់ បានសម្រេចដល់បារមីយ៉ាងឧក្រិដ្ឋក្នុងពោធិសម្ភារ ដើម្បីដល់ព្រមដោយអានុភាពដ៏ខ្ពង់ខ្ពស់ដូចនោះ ព្រោះដូច្នោះ សូម្បីយើងក៏គប្បីបដិបត្តិយ៉ាងនោះដោយប្រពៃក្នុងសិក្ខា មានសីលសិក្ខាជាដើមដែរ »។

ព្រះមហាបុរស មិនលះបង់នូវការព្យាយាម ដែលមាននូវសទ្ធាជាបុរេចារិក (ត្រាច់ទៅមុន) ដោយគិតថា « សូម្បីយើង ក៏នឹងបំពេញសិក្ខា ឱ្យបរិបូណ៌តាមលំដាប់ ដោយការបដិបត្តិ ហើយនឹងសម្រេចតាម ដល់នូវបទនោះ ដោយពិតប្រាកដ ដូច្នេះ ឈ្មោះថា យើងជាអ្នកធ្វើឱ្យ



បរិបូណ៌ក្នុងសីលទាំងឡាយដោយប្រពៃ » ។

ព្រះមហាបុរស ជាបុគ្គលបិទបាំងសេចក្តីល្អដែលជាគុណធម៌ បើកបង្ហាញ សម្តែងប្រាប់នូវទោសកំហុសរបស់ខ្លួន ។ មានសេចក្តីប្រាថ្នាតិច មានសន្តោស មានអធ្យាស្រ័យស្ងាត់ មិនច្របូកច្របល់ជំពាក់ទាក់ទិន ។ អត់ធន់ចំពោះទុក្ខ មិនតក់ស្លុត មិនរាយមាយ មិនក្រអឺត-ក្រអោង មិនអួតអាង មិនញាប់ញ័រ វាចាមិនអាក្រក់ មិនស្វែងរករឿងឈ្លោះទាស់ទែង មានឥន្ទ្រិយស្ងប់ ចិត្តស្ងប់ ប្រាសចាកការចិញ្ចឹមជីវិតខុសដោយប្រការផ្សេងៗ ។ ដល់ព្រមដោយអាចារៈ ( ការប្រព្រឹត្តត្រឹមត្រូវ ) និងគោចរៈ (ទីដែលគួរទៅ ) ឃើញភ័យក្នុងទោសសូម្បីមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខា ប្រារព្ធសេចក្តីព្យាយាម មានចិត្តមាំទាំ មិនគិតដល់កាយ និងជីវិត ។ លះបង់នូវឧបក្កិលេស មានសេចក្តីក្រោធ និងការចងនូវសេចក្តីក្រោធជាដើម ដែលជាហេតុនៃការទ្រុស្តសីលទាំងពួង ។ ជាបុគ្គលមិនត្រេកអរក្នុងការសម្រេចនូវគុណវិសេស ដែល

មានប្រមាណតិច ព្យាយាមដោយមិនរាថយ ដើម្បីសម្រេចនូវគុណវិសេសដ៏ក្រៃលែងឡើង ពោលគឺ មិនសន្តោសចំពោះកុសលឡើយ ។

ព្រះមហាបុរស ជាអ្នកនាំមនុស្សខ្វាក់ភ្នែក ប្រាប់បង្ហាញផ្លូវ ឱ្យសញ្ញាចង្អុលប្រាប់ដល់មនុស្សត្រចៀកថ្លង់ អនុគ្រោះប្រយោជន៍។មនុស្សគក៏ដូចគ្នា។ ឱ្យតាំង ឱ្យយានដល់មនុស្សពិការ ឬនាំទៅ ។ មនុស្សណាមិនមាននូវសទ្ធាក៏ព្យាយាមជួយឱ្យមនុស្សនោះមានសទ្ធា មនុស្សណាខ្ជិលក៏ព្យាយាម ជួយឱ្យមនុស្សនោះ ទៅជាឧស្សាហ៍ ។ល។ ពោលគឺជួយឱ្យសត្វទាំងឡាយរួចផុតចាកពីអកុសល ហើយតាំងនៅក្នុងកុសល ។ គប្បីជ្រាបចារិត្តសីលដូច្នេះឯង និងគប្បីជ្រាបសីលដោយពិស្តារ មាននៅក្នុងគម្ពីរវិសុទ្ធិមគ្គ ។

ព្រះមហាបុរស មិនបង្អោនទៅដើម្បីវិជ្ជា ៣ អភិញ្ញា ៦ បដិសម្ភិទា ៤ សាវកពោធិញ្ញាណ និងបច្ចេកពោធិញ្ញាណឡើយ ។

ព្រះមហាបុរស មិនបង្អោនទៅដើម្បីឱ្យផុតពីភាព



សៅហ្មង ក្នុងទុគ្គតិរបស់ខ្លួន មិនបង្អោនទៅដើម្បីរាជ-សម្បត្តិ ដើម្បីចក្រពត្តិសម្បត្តិ ដើម្បីទេវសម្បត្តិ ដើម្បីសក្កសម្បត្តិ ដើម្បីមារសម្បត្តិ ដើម្បីព្រហ្មសម្បត្តិ ឬសូម្បីតែសុគតិភពផងដែរ ។ ដោយពិត ព្រះមហាសត្វរមែងបង្អោនទៅ ដើម្បីឱ្យដល់នូវសីលាលង្ការ (អលង្ការគឺសីល) ដ៏យ៉ាងខ្ពង់ខ្ពស់ ក្នុងភាពព្រះអង្គជាព្រះសព្វញ្ញូនោះឯង ។ នេះគឺលំដាប់នៃការបដិបត្តិសីលបារមី ។

## ចំណុចបដិបត្តិនៃនេក្ខម្មបារមី

ព្រោះការកើតឡើងនៃកុសលចិត្ត ប្រព្រឹត្តទៅដោយការចេញចាកកាម និងភពទាំងឡាយ មានការឃើញទោសជាខាងដើម កំណត់ដោយបុគ្គលជាអ្នកឆ្លាតក្នុងឧបាយ មាននូវករុណា ឈ្មោះថានេក្ខម្មបារមី ។

ពិចារណាឃើញទោសរបស់កាម ដូចតទៅ :

-កាមទាំងឡាយមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន មាននូវសេចក្តីចង្អៀតចង្អល់ច្រើន មានការជាប់ជំពាក់ ទាក់ទិនជាមួយនឹងរបស់ ដែលមិនជាប្រយោជន៍

ច្រើនសន្ទឹកសន្ធាប់រាប់មិនអស់ ។

-ភាពជាឃរាវាស មិនងាយមានឱកាសរកសេចក្តីសុខក្នុងនេក្ខម្មៈបានឡើយ ហើយសេចក្តីប្រាថ្នាក្នុងកាមដូចយកអណ្តាតលិទ្ធកៀរទឹកឃ្មុំ ដែលជាប់នៅនឹងមុខដាវដ៏មុតដូច្នោះឯង ។

-កាមទាំងឡាយ តាំងនៅជាមួយនឹងសេចក្តីសៅហ្មងគ្រប់យ៉ាង មានការចង្អៀតចង្អល់ច្រើនដោយបុត្រនិងភរិយាជាដើម ។

-ក្រវល់ក្រវាយដោយការគិត តាំងចិត្តធ្វើនូវការងារច្រើនយ៉ាង មានកសិកម្ម និងពាណិជ្ជកម្មជាដើម ។

-ការបម្រើកាមមិនមានពេលសម្រាប់ខ្លួនឯង មានតែសញ្ញាវិបរិត ដូចគ្រឿងប្រដាប់កាយរបស់មនុស្សឆ្កួត ។

-មានការតបស្នងដោយរបស់មិនស្អាត មានការខូចកេរ្តិ៍ឈ្មោះជាដើម ។

-មិនឆ្អែត ដូចផឹកទឹកអំបិល ឬដូចគ្រាន់តែលិទ្ធទឹកសើមនៅនឹងចុងម្រាមដៃ ។



-មិនឆ្ងាញ់ មានការអន្ទះសា ត្រេកអរស្វែងរកព្រោះតែការស្រេកឃ្លានប៉ុណ្ណោះ ។

-ជាការប្រមូលរួបរួមនូវសេចក្តីវិនាស ដូចនុយបិទនឹងផ្លែសន្ទូច ។

-ជាហេតុឱ្យកើតទុក្ខរឿយៗ ដូចកម្តៅភ្លើង។

-មានការចងជាលក្ខណៈ ដូចជំរដាក់ចាប់ស្វា។

-ជាទីតាំងនៃភ័យ ដូចនៅផ្ទះជាមួយសត្រូវ ។

-ជាចំណីរបស់កិលេសមារ ដូចចិញ្ចឹមសត្រូវ ។

-មានទុក្ខសោកកើតពីការប្រែប្រួលទៅ ដូចសម្បត្តិមហោស្រព ។

-មានការដុតខាងក្នុង ដូចភ្លើងឆេះក្នុងដើមឈើដែលប្រហោង ។

-ដូចកំណាត់ឆ្អឹងដែលអត់សាច់ ដោយអត្ថថានឿយហត់អត់អំពើ ។

-ដូចដុំសាច់ដែលសត្វដណ្តើមគ្នា ដោយអត្ថថាលំបាកដ៏ក្រៃលែងក្នុងការហួងហែង ។

-ដូចរណ្តៅរងើកភ្លើង ដូចគប់ភ្លើងកាន់បញ្ច្រាសខ្យល់ ដូចការយល់សប្តិ ដូចកាំបិតនិងជ្រញ់ ។ល។

កាលដែល ព្រះសម្មាសម្ពុទ្ធត្រាស់ដឹងឡើងហើយ គួរបួសនៅក្នុងព្រះសាសនារបស់ព្រះអង្គ ។ គ្រាកាលដែលបួសហើយ គប្បីតាំងនៅក្នុងសីល គួរសមាទាននូវធុតង្គគុណ ដើម្បីសេចក្តីផូរផង់នៃសីលបារមីនោះឯង ។

ពិតណាស់ ព្រះមហាបុរសទាំងឡាយ សមាទាននូវធុតង្គធម៌ ហើយរក្សានូវធុតង្គធម៌ទាំងនោះដោយប្រពៃ ជាអ្នកប្រាថ្នាតិច សន្តោស មានសមាចារទាំងពួងបរិសុទ្ធដោយគុណ ជាអ្នកមានសីលដែលរកទោសមិនបាន ។ ជាអ្នកមានមន្ទិលគឺកិលេសខ្ពរចេញដោយទឹកគឺគុណធម៌ ។ មានការដុសខាត់កិលេស ស្ទាត់មិនច្របូកច្របល់ ប្រារព្ធសេចក្តីព្យាយាម ចិញ្ចឹមងាយ មានចិត្តតម្កល់មាំ ជាដើម។ តាំងនៅក្នុងអរិយវង្ស ចូលដល់ឈានដែលមានប្រភេទ ជាឧបចារនិងអប្បនា តាមសមគួរក្នុងអារម្មណ៍ ៤០ ដើម្បីសម្រេចនូវអរិយវង្ស គឺជាអ្នកត្រេកអរក្នុងភាវនា ។ ដោយ



ប្រការដូច្នេះឯង ដែលព្រះមហាបុរស បំពេញនូវនេក្ខម្មបារមីដោយប្រពៃហើយ ។

ក្នុងទីនេះគប្បីពោលនូវកម្មដ្ឋានដោយពិស្តារ និងវិធីភាវនានៃសមាធិភាវនា ៤០ គឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ អរូបជ្ឈាន ៤ សញ្ញាដែលសំគាល់ក្នុងអាហារថាបដិកូល ១ និងវវត្ថានៈគឺការកំណត់ធាតុ ៤ មានធាតុដី ជាដើម ១ ។ ទាំងអស់នេះលោកពោលទុកដោយពិស្តារហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ពិតណាស់ ក្នុងគម្ពីរវិសុទ្ធិមគ្គនោះ លោកពោលដោយអំណាចនៃសាវកពោធិសត្វតែម្យ៉ាង សូម្បីសីលក៏ដូចគ្នា តែក្នុងទីនេះ ពោលដោយបុគ្គលអ្នកឆ្លាតក្នុងឧបាយ ដោយអំណាចករុណានៃព្រះមហាពោធិសត្វ សេចក្តីផ្សេងគ្នានេះមានដោយប្រការដូច្នេះ ។ គប្បីជ្រាបលំដាប់នៃនេក្ខម្មបារមីក្នុងទីនេះ ដោយប្រការដូច្នេះឯង ។

## ចំណុចបដិបត្តិនៃបញ្ញាបារមី

ពន្លឺអ្វីស្មើដោយបញ្ញាមិនមានឡើយ ។

បញ្ញាជាពន្លឺភ្លឺស្វាង រមែងមិនរួមជាមួយនឹងមោហៈ ដែលជាសភាវៈងងឹតឡើយ ព្រោះហេតុដូច្នោះ ព្រះ-បរមពោធិសត្វ ដែលបំណងនឹងបំពេញនូវបញ្ញាបារមីឱ្យសម្បូណ៌ ទើបបានវៀរចាកនូវ **ហេតុនៃមោហៈ** មានដូចតទៅនេះគឺ :

-ការច្រណែន

-ការស្ពឹកស្រពន់ទម្រន់ខ្លួន

-ការជ្រប់ងប់ទៅក្នុងសេចក្ដីសោក

-ការខ្ជិលច្រអូស

-ការត្រេកអរក្នុងការច្របូកច្របល់ដោយពួកគណៈ

-ការដេកលក់ច្រើន

-ការមិនតាំងចិត្តឱ្យពិតប្រាកដ

-ការមិនចាប់អារម្មណ៍ក្នុងញាណ

-ការប្រកាន់ខ្លួន

-ការមិនសាកសួរ

-ការមិនរក្សារាងកាយឱ្យល្អ



-ការមិនតម្កល់ចិត្តឱ្យតាំងមាំ

-ការសេពគប់បុគ្គលអន់ថយដោយបញ្ញា

-ការមិនចូលទៅជិតបុគ្គលដែលមានបញ្ញា

-ការមើលងាយខ្លួនឯង

-ការគិតត្រិះរិះខុស

-ការប្រកាន់វិបរិត គឺប្រកាន់អ្វីៗប្លែកៗដែលខុសពីធម្មតានៃការពិត បានដល់ទិដ្ឋិ ៦២

-ការមិនមាននូវសេចក្ដីសង្វេគ

-ការមាននូវនីវរណៈ ៥

-ការដែលសេពគប់ក្នុងព្រះធម៌ ឬស្វែងយល់អំពីព្រះធម៌ដោយសង្ខេបតិចតួចពេក ដែលធ្វើឱ្យបញ្ញាដែលមិនទាន់កើតឡើង រមែងមិនកើតឡើង បញ្ញាដែលកើតឡើងហើយ រមែងសាបសូន្យ ។

ព្រះមហាបុរស វៀរចាកហេតុនៃសេចក្ដីវង្វេងទាំងអស់នេះ ហើយធ្វើនូវសេចក្ដីព្យាយាមក្នុងពាហុសច្ចៈ (ការចេះដឹងច្រើន) និងក្នុងឈានជាដើម ដោយប្រការ

ដូច្នេះឯង ។

គប្បីជ្រាបពីការចែកលក្ខណៈនៃពាហុសច្ចៈ ដូចតទៅនេះគឺ ពាហុសច្ចៈក្នុងខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ អរិយសច្ចៈ ៤ ឥន្ទ្រិយ ២២ បដិច្ចសមុប្បាទ ១២ សតិប្បដ្ឋាន ៤ និងប្រភេទនៃធម៌មានកុសលជាដើម ។ វិជ្ជាការដែលមិនមានទោសក្នុងលោក ការព្យាករពិសេសដែលប្រកបដោយវិធីនាំប្រយោជន៍សុខ ឱ្យដល់សត្វទាំង-ឡាយ ។ គប្បីឱ្យកើតសុតមយប្បញ្ញា ដោយការចុះកាន់សុតវិស័យគ្រប់យ៉ាងគ្រប់ប្រការ ដោយបញ្ញាដែលជាការឆ្លាតក្នុងឧបាយជាខាងដើម ដោយសតិ ដោយវីរិយៈ ដោយការរៀន ការស្តាប់ ការទ្រទ្រង់ចាំទុក ការសន្សំ ការសាកសួរដោយល្អ ហើយឱ្យអ្នកដទៃតាំងនៅក្នុងបញ្ញានោះ ដោយប្រការដូច្នោះឯង ។

បញ្ញាដែលជាបដិភាណ ដែលនឹងធ្វើឱ្យសត្វទាំង-ឡាយ បានសម្រេចដល់ទិសដៅ ។ ជាអ្នកឆ្លាតក្នុងហេតុនៃសេចក្តីចម្រើន ហេតុនៃសេចក្តីវិនាស និងជាអ្នកឆ្លាត



ក្នុងឧបាយគេចចេញពីហេតុនៃសេចក្តីវិនាស តាំងនៅក្នុងហេតុនៃសេចក្តីចម្រើន ឆ្លាតក្នុងអ្វីដែលគួរធ្វើ ។ ជាបុគ្គលដែលញុាំងសត្វទាំងឡាយ ឱ្យមានការសម្លឹង ពិនិត្យដោយយោនិសោមនសិការ ទៅក្នុងអាការនៃសភាវធម៌ មានខន្ធជាដើម គប្បីឱ្យកើតចិន្តាមយប្បញ្ញាដល់សត្វទាំងឡាយនោះៗ ។

ម្យ៉ាងទៀត ជាអ្នកញុាំងលោកិយប្បញ្ញា ឱ្យកើតឡើងដោយអំណាចនៃការកំណត់លក្ខណៈរបស់ខ្លួន និងសាមញ្ញលក្ខណៈរបស់ខន្ធជាដើម គប្បីឱ្យសម្បូណ៌ដោយភាវនាមយប្បញ្ញា ដែលជាចំណែកខាងដើម ។ ពិតណាស់ នេះគ្រាន់តែជានាមរូបដែលកើតឡើង និងរលត់ទៅដោយបច្ច័យទាំងឡាយតាមសមគួរ ។ ក្នុងរឿងនេះមិនមានអ្នកណាធ្វើដោយខ្លួនឯង ឬអ្នកដទៃធ្វើឡើយ ជាការមិនទៀងព្រោះមានហើយត្រឡប់ជាមិនមានវិញ ជាទុក្ខ ព្រោះកើតឡើងហើយ ត្រូវវិនាសបែកធ្លាយ ជាអនត្តា ព្រោះមិននៅក្នុងអំណាចខ្លួន ។

ដោយហេតុនោះ ព្រះមហាបុរស កំណត់ដឹងធម៌ខាងក្នុង និងធម៌ខាងក្រៅ មិនឱ្យសល់ លះបង់ការជាប់ជំពាក់ក្នុងធម៌នោះ និងឱ្យអ្នកដទៃលះបង់ការជាប់ជំពាក់នោះ ក្នុងធម៌នោះផងដែរ ដោយអំណាចនៃករុណាធម៌តែម្យ៉ាងប៉ុណ្ណោះ។ ព្រះពុទ្ធគុណនៅមិនទាន់មកដល់កណ្តាប់ដៃដរាបណា ដរាបនោះ ព្រះមហាបុរសញ៉ាំងសត្វទាំង-ឡាយឱ្យតាំងនៅក្នុងបញ្ញាទាំង ៣ គឺ បញ្ញាថ្នាក់ស្តាប់ ១ បញ្ញាថ្នាក់គិតពិចារណា ១ និងបញ្ញាថ្នាក់អប់រំចម្រើន ១ ធ្វើឱ្យមានសេចក្តីចម្រើនជាភិយ្យោភាព ញ៉ាំងឈានវិមោក្ខសមាធិ និងសមាបត្តិ ព្រមទាំងអភិញ្ញាដែលជាលោកិយឱ្យដល់នូវសេចក្តីជំនាញ ឱ្យសម្រេចដល់ទីបំផុតនៃបញ្ញា ។

ក្នុងអភិញ្ញាជាលោកិយនោះ ភាវនាបញ្ញា គឺ អភិញ្ញាទាំងឡាយបានដល់ **ឥទ្ធិវិធញ្ញាណ** (អភិញ្ញាខាងសម្តែងឫទ្ធិ) **ទិព្វសោតធាតុញ្ញាណ** (អភិញ្ញាខាងត្រចៀកទិព្វ) **ចេតោបរិយញ្ញាណ** (អភិញ្ញាខាងដឹងចិត្តអ្នកដទៃ) **បុព្វេនិវាសានុស្សតិញ្ញាណ** (អភិញ្ញាខាងរលឹកជាតិមុនៗ)



**ទិព្វចក្ខុញ្ញាណ** (អភិញ្ញាខាងភ្នែកទិព្វ) **យថាកម្មូបគញ្ញាណ** (អភិញ្ញាខាងដឹងកុសលកម្មនិងអកុសលកម្មក្នុងជាតិមុនៗ) **អនាគតំសញ្ញាណ** (អភិញ្ញាខាងដឹងអនាគត) ។

**ឥទ្ធិវិធញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៧ គឺ បរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អតីតារម្មណ៍ ១ អនាគតារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ និងពហិទ្ធារម្មណ៍ ១ ។

**ទិព្វសោតធាតុញ្ញាណ** ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ គឺ បរិត្តារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ និងពហិទ្ធារម្មណ៍ ១ ។

**ចេតោបរិយញ្ញាណ** ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ គឺ បរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អប្បមាណារម្មណ៍ ១ មគ្គារម្មណ៍ ១ អតីតារម្មណ៍ ១ អនាគតារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ និងពហិទ្ធារម្មណ៍ ១ ។

**បុព្វេនិវាសានុស្សតិញ្ញាណ** ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ គឺបរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១

អប្បមាណារម្មណ៍ ១ មគ្គារម្មណ៍ ១ អតីតារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ និងនវត្តព្វារម្មណ៍ ១ ។

**ឆិព្វចក្ខុញ្ញាណ** ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ គឺ បរិត្តារម្មណ៍ ១ បច្ចុប្បន្នារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ និងពហិទ្ធារម្មណ៍ ១ ។

**យថាកម្មុបគញ្ញាណ** ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ គឺ បរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អតីតារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ និងពហិទ្ធារម្មណ៍ ១ ។

**អនាគតំសញ្ញាណ** ប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ គឺ បរិត្តារម្មណ៍ ១ មហគ្គតារម្មណ៍ ១ អប្បមាណារម្មណ៍ ១ មគ្គារម្មណ៍ ១ អនាគតារម្មណ៍ ១ អជ្ឈត្តារម្មណ៍ ១ ពហិទ្ធារម្មណ៍ ១ និង នវត្តព្វារម្មណ៍ ១ [១] ។

នៅក្នុងអដ្ឋកថា **បុព្វនិវាសានុស្សតិញ្ញាណនិទ្ទេស**បាន សម្តែងថា :

១.ញាណទាំង ៧ មានក្នុងបដិសម្ភិទាមគ្គ ញាណនិទ្ទេស បិដក លេខ ៦៩ និងអដ្ឋកថា ។ នវត្តព្វារម្មណ៍ បានដល់ បញ្ញត្តិ



អន្យតិរ្ថិយទាំងឡាយ រមែងរលឹកបាន ៤០ កប្ប មិនលើសពីនេះឡើយ ព្រោះហេតុអ្វី ? ព្រោះពួកអន្យតិរ្ថិយមានបញ្ញាអន់ខ្សោយ ។ ពិតណាស់ បញ្ញារបស់ពួកអន្យតិរ្ថិយនោះ ទន់ខ្សោយព្រោះមិនមានការកំណត់ដឹងនាមរូប ។

ពុទ្ធសាវ័កធម្មតា រមែងរលឹកបាន ១ រយកប្បខ្លះ ១ ពាន់កប្បខ្លះ ព្រោះមានបញ្ញាចាស់ក្លា ។ ឯមហាសាវ័ក ៨០ អង្គ រលឹកបាន ១សែនកប្ប ។ ព្រះអគ្គសាវ័កទាំងពីររលឹកបាន ១អសង្ខេយ្យ និង ១សែនកប្ប [១] ។

ព្រះបច្ចេកពុទ្ធរលឹកបាន ២ អសង្ខេយ្យ និង ១ សែនកប្ប ព្រោះអភិនីហាររបស់ព្រះបច្ចេកពុទ្ធទាំងនោះមានប្រមាណត្រឹមនេះ ។

RBHsmµasm<úT§Ta MgLayរលឹកបានមិនមានកំណត់។

១.ក្នុងអដ្ឋកថា ឯតទគ្គៈរបស់ព្រះនាងភទ្ទាកច្ចានាថេរី (រាហុល-មាតា ) សម្តែងថា ក្នុងព្រះពុទ្ធសាសនានេះ អ្នករលឹកជាតិបាន ១ អសង្ខេយ្យ

និង ១សែនកប្ប មាន ៤ អង្គ គឺព្រះអគ្គសាវកទាំងពីរអង្គ និងព្រះពាកុលត្ថេរ ១ អង្គ ព្រះនាងភទ្ទាកច្ចានាថេរី ១ អង្គ ។

ក៏បណ្ដាបុគ្គលទាំង ៦ ពួកនោះ មានការរលឹកជាតិមុនមានសេចក្ដីប្រៀបដូចតទៅនេះគឺ :

-ការឃើញជាតិមុន របស់ពួកអន្យតិរ្ថិយ ដូចពន្លឺអំពិលអំពែក ។

-ញាណរបស់ព្រះសាវ័កធម្មតា ដូចពន្លឺប្រទីប ។

-ញាណរបស់ព្រះមហាសាវ័ក ដូចពន្លឺគប់ភ្លើង ។

-ញាណរបស់អគ្គសាវ័កទាំងពីរដូចរស្មីផ្កាយព្រឹក។

-ញាណរបស់ព្រះបច្ចេកពុទ្ធ ដូចរស្មីព្រះចន្ទ ។

-ញាណរបស់ព្រះសម្មាសម្ពុទ្ធ រមែងប្រាកដដូចមណ្ឌលព្រះអាទិត្យក្នុងសរទកាល ប្រដាប់ដោយរស្មី ១ ពាន់ដួង ។

ភាវនាបញ្ញា ដែលជាលោកិយ និងលោកុត្តរ ដែលបុគ្គលមានការសន្សំដោយការរៀន ការសាកសួរក្នុងធម៌ដែលជាភូមិឋាន មានខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ អរិយ-



សច្ចៈ និង បដិច្ចសមុប្បាទជាដើម ហើយតាំងនៅក្នុងវិសុទ្ធិ ២ ដែលជាឫសគល់ គឺ **សីលវិសុទ្ធិ** និង **ចិត្តវិសុទ្ធិ** ហើយគប្បីចម្រើននូវវិសុទ្ធិ ៥ ឱ្យសម្បូណ៌ គឺ

**ទិដ្ឋិវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃបញ្ញាក្នុងការកំណត់ដឹង និងចែកនូវនាមរូប ១ ។

**កង្ខាវិតរណវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃបញ្ញាក្នុងការឆ្លងផុតពីសេចក្ដីសង្ស័យ ១ ។

**មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃបញ្ញាក្នុងការឃើញផ្លូវ និងមិនមែនផ្លូវ ១ ។

**បដិបទាញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃបញ្ញាក្នុងការដឹងផ្លូវបដិបត្តិ ១ ។

**ញាណទស្សនវិសុទ្ធិ** សេចក្ដីបរិសុទ្ធនៃញាណ-ទស្សនៈ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ១ ។

វិធីការឱ្យសម្រេច ( បច្ច័យ ) នៃភាវនាបញ្ញាទាំងនេះលោកពោលទុកដោយពិស្ដារហើយ ក្នុងវិសុទ្ធិមគ្គ ដោយប្រការទាំងពួង ដោយន័យមានជាអាទិ៍ថា ព្រះយោគីដែល

ជាអាទិកម្មិក បំណាងនិងធ្វើការសម្តែងឫទ្ធិ ឱ្យមនុស្សម្នាក់ទៅជាច្រើននាក់ជាដើម និងដោយន័យ គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ជាដើម ។ គប្បីជ្រាបដោយន័យតាមដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះៗឯង គឺជាបញ្ញាដែលមកហើយ ដោយអំណាចនៃសាវកពោធិសត្វ ក្នុងភាវនាបញ្ញានោះតែម៉្យាង ។

ក្នុងទីនេះ ដោយអំណាចនៃ ព្រះមហាពោធិសត្វ គប្បីពោលដល់ភាវនាបញ្ញា ដែលមានការឆ្លាតក្នុងឧបាយ គឺករុណា ជាដើមដំបូង មានការតាំងវិបស្សនាទុកក្នុង **បដិបទាញាណទស្សនវិសុទ្ធិ** ប៉ុណ្ណោះ មិនបានចូលដល់ **ញាណទស្សនវិសុទ្ធិ** ឡើយ នេះជាសេចក្តីផ្សេងគ្នា ។ គប្បីជ្រាបលំដាប់នៃការបដិបត្តិនូវបញ្ញាបារមី ក្នុងទីនេះ ដោយប្រការដូច្នេះឯង ។

## ចំណុចបដិបត្តិនៃវីរិយបារមី

ឆ្លងសេចក្តីទុក្ខបានដោយការព្យាយាម ។

ព្រះមហាពោធិសត្វ ដែលបំពេញបារមីដើម្បីសម្មា-សម្ពោធិញ្ញាណ គប្បីជាអ្នកប្រកបនូវសេចក្តីព្យាយាមគ្រប់ពេល ជាប្រយោជន៍ដើម្បីឱ្យបារមីពេញបរិបូណ៌ ដោយការបំពេញជាប់តគ្នាជានិច្ច ។ គ្រប់ពេលវេលាជារហូត ព្រះមហាសត្វពិចារណារាល់ៗថ្ងៃថា ថ្ងៃនេះយើងនឹងសន្សំបុញ្ញសម្ភារ ឬញាណសម្ភារអ្វីហ្ន៎ ឬថា យើងនឹងធ្វើនូវប្រយោជន៍ដើម្បីអ្នកដទៃយ៉ាងណាទើបល្អប្រពៃ ។

-បុគ្គលដែលប្រាថ្នានូវសម្មាសម្ពោធិញ្ញាណ គប្បីធ្វើនូវសេចក្តីព្យាយាម ដើម្បីប្រយោជន៍ដល់សត្វដូចតទៅៈ

-គប្បីមានចិត្តមាំទាំដោយមិនគិតដល់កាយនិងជីវិត លះបង់នូវវត្ថុដែលជាទីហួងហែងរបស់ខ្លួន ដើម្បីជួយដល់សត្វលោក ។

-កាលបើធ្វើកម្មយ៉ាងណាមួយ ដោយកាយ ឬវាចា គប្បីធ្វើកម្មនោះទាំងអស់ ដោយចិត្តបង្អោនទៅក្នុងសម្មា-សម្ពោធិញ្ញាណតែប៉ុណ្ណោះ ។

-គប្បីមានចិត្តផុតចាកកាមទាំងឡាយ ដ៏យ៉ាងហ្មត់ចត់ ។

-គប្បីជាអ្នកឆ្លាតក្នុងឧបាយ ហើយគប្បីបដិបត្តិក្នុងបារមីទាំងពួង ដែលគួរធ្វើ ។

-គប្បីប្រារព្ធសេចក្ដីព្យាយាម ក្នុងប្រយោជន៍របស់សត្វនោះៗ ។

-គប្បីអត់ធន់ក្នុងអារម្មណ៍ទាំងពួងដែលគួរ ប្រាថ្នា និងមិនគួរប្រាថ្នាជាដើម ។

-គប្បីមិននិយាយខុសពីសេចក្ដីពិត ។

-គប្បីផ្សាយមេត្តា និងករុណា ដល់សត្វទាំងពួង ដោយមិនចំពោះ ។

-ការកើតឡើងនៃទុក្ខយ៉ាងណាមួយ ដែលប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ គប្បីសង្ឃឹមការកើតឡើងនៃទុក្ខទាំងឡាយនោះ ឱ្យមានចំពោះខ្លួនវិញ ។

-គប្បីអនុមោទនាបុណ្យរបស់សត្វទាំងពួង ។



-គប្បីពិចារណារឿយៗ ដល់ភាពនៃព្រះសម្មាសម្ពុទ្ធ ដែលជាធំ មានអានុភាពច្រើន ។

ក៏ដោយឧបាយនេះ ព្រះមហាពោធិសត្វ ប្រកបនូវការខ្វល់ខ្វាយក្នុងទានជាដើម មានកម្លាំងចិត្តខ្លាំងក្លា មានការព្យាយាមមាំ ចូលទៅសន្សំនូវបុញ្ញសម្ភារ និងញាណ-សម្ភារ ដែលរកប្រមាណមិនបានរាល់ៗថ្ងៃ ។

ម្យ៉ាងទៀត ដើម្បីឱ្យសត្វបានបរិភោគ និងដើម្បីគ្រប់គ្រងសត្វ ទើបលះបង់រាងកាយ និងជីវិតរបស់ខ្លួន ។ គប្បីស្វែងរកនូវគ្រឿងកម្ចាត់ទុក្ខ មានទុក្ខ ព្រោះស្រេក ព្រោះឃ្លាន ក្ដៅ រងា ជាដើម ធ្វើឱ្យសត្វបានទទួលនូវសេចក្ដីសុខ ដែលកើតអំពីការកម្ចាត់ទុក្ខ ពោលគឺឱ្យបានទទួលនូវសេចក្ដីសុខ ព្រោះមិនមានកម្ដៅផ្លូវកាយ និងផ្លូវចិត្ត ក្នុងសួនឧទ្យាន ក្នុងប្រាសាទ ក្នុងស្រះជាដើម ឬក៏ក្នុងដងព្រៃដែលគួររីករាយ ។ ព្រោះបានស្ដាប់មកថា ព្រះសម្មាសម្ពុទ្ធ ព្រះអនុពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះមហា-ពោធិសត្វទាំងឡាយ តាំងនៅក្នុងនេក្ខម្មប្បដិបត្តិ រមែង

សោយសុខក្នុងឈាន និងសមាបត្តិ យ៉ាងនេះមួយៗ ដែលជាសុខវិហារធម៌ក្នុងបច្ចុប្បន្ន ព្រះមហាបុរស ក៏មានបំណងនឹងធ្វើនូវសេចក្ដីសុខទាំងអស់នោះ ឱ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ ដោយមិនចោះចំពោះ ។

ព្រះមហាបុរស បានបង្អោននូវបីតិ បស្សទ្ធិ សុខ សមាធិ យថាភូតញ្ញាណ (ឃើញសភាវធម៌តាមសេចក្ដីពិត ) ដែលកើតមកពីការសម្រេចនូវគុណវិសេស តាមដែលខ្លួនបានសោយហើយ ឱ្យចូលទៅក្នុងសត្វទាំងឡាយ។

ព្រះមហាបុរសបរមពោធិសត្វ ឃើញពពួកសត្វលិចចុះនៅក្នុងសង្សារទុក្ខ មានទុក្ខដ៏ក្រៃលែង ឃើញអភិសង្ខារទុក្ខ និងឃើញកិលេសដែលជានិមិត្តនៃសង្សារ-វដ្ដ ។ក្នុងពពួកសត្វនោះៗ ឃើញសត្វនរកសោយនូវទុក្ខវេទនាដ៏យ៉ាងខ្លាំងក្លា ជាមហាទារុណ ។ សត្វតិរច្ឆានសោយទុក្ខធ្ងន់ដោយការក្រោធដល់គ្នានឹងគ្នា ធ្វើឱ្យក្ដៅក្រហាយ បៀតបៀន សម្លាប់ ចាប់ជាអាហារ ស្រេកឃ្លាន ។ល។ ប្រេត មាននិជ្ឈាមតណ្ហិកប្រេតជាដើម ដុត



រោលក្នុងរាងកាយ ដោយកងភ្លើង មានភ្លើងកើតពីកម្មជាដើម យំស្រែករកអាហារ មានទឹកមាត់កំហាកដែលគេស្ដោះចោលជាដើម ហើយក៏សោយនូវទុក្ខធំ ។

សត្វនរកប្រេត តិរច្ឆាន ដល់នូវសេចក្ដីទុក្ខលំបាកដ៏ក្រៃលែង ។ មនុស្សលំបាកព្រោះការស្វែងរកអាហារជាហេតុ លំបាកព្រោះការទទួលទុក្ខទោស ទារុណកម្មក្នុងពន្ធនាគារ ត្រូវវាយដំ ត្រូវស្រេកឃ្លានព្រោះខ្វះខាតអាហារ ។ល។ ម្យ៉ាងទៀតមនុស្សត្រូវសោយទុក្ខ ព្រោះសល់ផលកម្មពីអបាយភូមិ ។ កាមាវចរទេវតា ត្រូវសេចក្ដីក្ដៅក្រហាយដោយរាគៈជាដើមដុតរោល មានចិត្តរវើរវាយក្នុងការបរិភោគកាមគុណ ក្ដៅក្រហាយមិនស្ងប់ ដូចភ្លើងឆេះព្រៃក្នុងរដូវប្រាំង អណ្ដាតភ្លើងឆ្លូលឆាបវីវក់ដោយកម្លាំងខ្យល់ ។ រូបាវចរទេវតា និងអរូបាវចរទេវតា មានអាយុវែង រស់នៅបានយូរ ដូចបក្សីដែលស្ទុះទៅឰដ៏អាកាសបានឆ្ងាយ ដោយការព្យាយាមខ្លាំង ឬក៏ដូចព្រួញដែលគេបាញ់ចេញទៅក្នុងទីឆ្ងាយ តែក្នុងទីបំផុតក៏ធ្លាក់ ។ សង្ខារ-

ធម៌ទាំងឡាយមិនទៀង មានការកើតឡើងហើយ រមែងមានសេចក្តីវិនាសជាទីបំផុត ដូច្នេះ ទើបសត្វលោកមិនកន្លងផុតចាកជរាមរណៈទៅបានឡើយ ។

នៅមានសេចក្តីសង្វេគច្រើនបែប ច្រើនយ៉ាងទៀត ដែលប្រាកដដល់ព្រះបរមពោធិសត្វ ហើយព្រះបរមពោធិសត្វ ក៏ផ្សាយនូវមេត្តា និងករុណាទៅកាន់សត្វទាំងឡាយ ដោយមិនចោះចំពោះ ។



អ្នកសន្សំនូវពោធិសម្ភារ ដោយកាយវាចា និងចិត្ត ជាលំដាប់យ៉ាងនេះ បារមីរមែងពេញពោរ ។ ដូច្នេះបុគ្គលគប្បីធ្វើដោយសេចក្តីគោរព ធ្វើឱ្យជាប់តគ្នា ប្រព្រឹត្តមិនធូរថយ ញុំាងឧស្សាហៈឱ្យប្រព្រឹត្តទៅ នេះគឺជាការបំពេញនូវវីរិយបារមីឱ្យបរិបូណ៌ ។

ម្យ៉ាងទៀត សេចក្តីព្យាយាម ដើម្បីបានជាព្រះសម្មាសម្ពុទ្ធ គឺជាអចិន្តេយ្យ និងជាទីតាំងនៃការសន្សំគុណ ដែលរកប្រមាណមិនបាន សម្បូណ៌ឱឡារិកសន្ធឹកក្រៃលែង ប្រាសចាកមន្ទិល មិនមានអ្វីប្រៀប មិនមានឧបក្កិលេស ។

នេះជាអានុភាពនៃអចិន្តេយ្យនោះឯង ដែលមនុស្សទាំងឡាយសូម្បីបានស្តាប់ឮហើយ ក៏មិនងាយនឹងបដិបត្តិបានឡើយ ។

អភិនីហារចិត្តុប្បាទ ពុទ្ធភូមិ សង្គហធម៌ ករុណា ជាកិច្ចដ៏ធំក្រៃលែង ។

ការបដិបត្តិដោយព្យាយាម ក្នុងពោធិសម្ភារមាន ជាអាទិ៍ដូចតទៅ :



-ការអត់ធន់ក្នុងការពិនិត្យ ដែលជាបច្ច័យដ៏វិសេស ក្នុងការធ្វើឱ្យច្បាស់ក្នុងពុទ្ធធម៌ ។

-ការមិនចូលទៅដោយ គ្រាន់តែស្ទាបអង្អែលក្នុងពុទ្ធធម៌ ។

-សេចក្តីសំគាល់ក្នុង សត្វទាំងពួងថាជាបុត្រដ៏ជាទីស្រឡាញ់ ។

-ការព្រមទទួលនូវសង្សារទុក្ខព្រោះករុណាសត្វ ។

-ការបរិច្ចាគនូវទេយ្យធម៌ទាំងពួង និងការមានចិត្តត្រេកអរក្នុងការបរិច្ចាគនោះ ។

-ការអធិដ្ឋាននូវអធិសីលជាដើម និង ការមិនញាប់ញ័រក្នុងអធិដ្ឋាននោះឯង ។

-បីតិ និងបាមោជ្ជក្នុងកុសលកិរិយា ។

-ភាពនៃចិត្តដែលបង្អោនទៅរកវិវេក ។

-ការប្រកបឈានរឿយៗ ។

-ការមិនតិះដៀលនូវធម៌ដែលមិនមានទោស ។

-សម្តែងធម៌តាមដែលបានស្តាប់មក ដោយមានអធ្យាស្រ័យទំនុកបម្រុងដល់អ្នកដទៃ ឱ្យសត្វទាំងឡាយតាំងនៅក្នុងរបៀបវិន័យ ។

-ភាពមាំទាំក្នុងការចាប់ផ្តើម ។

-ឆ្លាតហើយ ក្លាហាន ។

-មិនធ្វើនូវសេចក្តីវិនាស ឬការខូចខាតបាត់បង់ឱ្យដល់អ្នកដទៃ ។

-តាំងមាំក្នុងសច្ចៈ ។

-ជំនាញក្នុងសមាបត្តិ ។

-មានកម្លាំងក្នុងអភិញ្ញា ។



-ដឹងនូវត្រៃលក្ខណ៍ ។

-សន្សំបារមីក្នុងលោកុត្តរមគ្គ ដោយការប្រកបព្យាយាមក្នុងសតិប្បដ្ឋានជាដើម និង ឈានចុះកាន់លោកុត្តរធម៌ ៩ ។

ការបដិបត្តិដើម្បីពោធិសម្ភារទាំងអស់នេះ រមែងសម្រេចដោយអានុភាពនៃវីរិយៈ ។

ព្រោះហេតុនោះ តាំងតែពីការចាប់ផ្តើមអភិនីហាររហូតដល់ការត្រាស់ដឹង ព្រះមហាបុរសមិនដាក់ចុះនូវធុរៈញ៉ាំងនូវសេចក្តីព្យាយាមឱ្យសម្បូណ៌ ដោយគោរព ដែលជាហេតុនាំមកនូវគុណវិសេស ដោយប្រការដូច្នេះ ។

កាលបើសេចក្តីព្យាយាម តាមដូចដែលបានពោលហើយ មាននូវភាពបរិបូណ៌ គប្បីជ្រាបការបដិបត្តិដោយន័យនេះថា ពោធិសម្ភារទាំងអស់ មានខន្តី សច្ចៈ អធិដ្ឋានទាន សីលជាដើម រមែងសម្បូណ៌ពេញលេញ ព្រោះអាស្រ័យនូវសេចក្តីព្យាយាមហ្នឹងឯង ។ គប្បីជ្រាបលំដាប់នៃការបដិបត្តិនូវវីរិយបារមី ដោយប្រការដូច្នេះឯង ។

## សង្ខេបចំណុចបដិបត្តិនៃបារមីទាំងអស់

ការធ្វើសេចក្តីអនុគ្រោះ ដោយការបរិច្ចាគនូវឧបករណ៍ផ្តល់សេចក្តីសុខ ឱ្យដល់សត្វទាំងឡាយ ឈ្មោះថាបដិបត្តិដោយការឱ្យទាន ។

ហេតុទាំងឡាយ មានជាអាទិ៍ គឺការរក្សាជីវិត សម្បត្តិ បុត្រភរិយាអ្នកដទៃ ការពោលនូវពាក្យពិត មិនឱ្យបែកគ្នា ពីរោះហើយមានប្រយោជន៍ និងមិនបៀតបៀនសត្វទាំងឡាយនោះៗ ឈ្មោះថាបដិបត្តិដោយសីល ។



ការប្រព្រឹត្តនូវអំពើជាប្រយោជន៍ច្រើនយ៉ាង ដោយការទទួលមរតកហើយឱ្យទាន បរិច្ចាគលះបង់មិនជាប់ជំពាក់ ឈ្មោះថាបដិបត្តិដោយនេក្ខម្មៈ ។

ភាពជាអ្នកឆ្លាតក្នុងឧបាយ ធ្វើប្រយោជន៍ឱ្យដល់សត្វទាំងឡាយ ឈ្មោះថាបដិបត្តិដោយបញ្ញា ។

ការមាននូវឧស្សាហៈ ចាប់ផ្តើមមិនរាថយ ក្នុងការងារនោះៗ ឈ្មោះថាបដិបត្តិដោយវីរិយៈ ។

ការដែលអត់ទ្រាំបានចំពោះអារម្មណ៍ ដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា អត់ធន់ក្នុងការសម្លឹងសេចក្តីពិត ឈ្មោះថាបដិបត្តិដោយខន្តី ។

ការមិនលលួងបោកបញ្ឆោត ការបំពេញធម៌មានឧបការៈឱ្យប្រាកដ សមាទានសិក្សា និងការមិននិយាយខុសពីសេចក្តីពិតជាដើមដល់សត្វនោះៗ ឈ្មោះថាបដិបត្តិដោយសច្ចៈ ។



សូម្បីធ្លាក់ក្នុងសេចក្តីវិនាស ក៏មិនបានញាប់ញ័រក្នុងការបំពេញធម៌មានឧបការៈដែរ ឈ្មោះថាបដិបត្តិដោយអធិដ្ឋាន ។

គិតតែប្រយោជន៍សុខដល់សត្វទាំងឡាយ ឈ្មោះថាបដិបត្តិដោយមេត្តា ។

ការមិនមានកង្វល់ មិនចង្អៀតចង្អល់ដល់ភាពខុសប្រក្រតី គឺសេចក្តីចម្រើន និងសេចក្តីវិនាស នៃសត្វទាំងឡាយ ក្នុងការដែលសត្វទាំងឡាយប្រព្រឹត្តទៅតាមកម្ម ឈ្មោះថាបដិបត្តិដោយឧបេក្ខា ។

ព្រះមហាបុរស ប្រោសព្វសត្វទាំងឡាយច្រើនមិនមានប្រមាណយ៉ាងនេះ ដោយប្រការដូច្នេះហើយ ជាអ្នកសន្សំនូវបុញ្ញសម្ភារ និងញាណសម្ភារ រកប្រមាណមិនបាន ។ ព្រះមហាពោធិសត្វ មានការទទួលរ៉ាប់រងស្មើជានិច្ច អនុគ្រោះដល់សព្វសត្វ គប្បីជ្រាបថា នេះជាការបដិបត្តិក្នុងបារមីទាំងឡាយ ។

# ការចែកបារមី

បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ មាន ដូចតទៅ :

ការបរិច្ចាគបុត្រភរិយា និងឧបករណ៍មានទ្រព្យ ជាដើម ជាទានបារមី ។ ការបរិច្ចាគអវយវៈជាទានឧប-បារមី ។ ការបរិច្ចាគជីវិតរបស់ខ្លួន ជាទានបរមត្ថបារមី ។

សីលបារមី សីលឧបបារមី សីលបរមត្ថបារមី ដោយការមិនប្រព្រឹត្តកន្លង ព្រោះហេតុមានបុត្រ និង ភរិយាជាដើម ។

នេក្ខម្មបារមី នេក្ខម្មឧបបារមី នេក្ខម្មបរមត្ថបារមី ដោយការកាត់អាល័យក្នុងវត្ថុ ៣ យ៉ាងនោះៗ ហើយចេញបួស ។

បញ្ញាបារមី បញ្ញាឧបបារមី បញ្ញាបរមត្ថបារមី ដោយការប្រមូលតណ្ហាក្នុងឧបករណ៍បុត្រភរិយា អវយវៈ



និងជីវិត បិទទុក មិនឱ្យចូលមកលាយឡំក្នុងការវិនិច្ឆ័យ អ្វីជាប្រយោជន៍ អ្វីមិនមែនជាប្រយោជន៍ របស់សត្វទាំងឡាយ ។

វីរិយបារមី វីរិយឧបបារមី វីរិយបរមត្ថបារមី ដោយការព្យាយាមបរិច្ចាគជាដើម តាមប្រភេទនៃវត្ថុទាំង ៣ ដូចដែលបានពោលហើយ និងទៅតាមប្រភេទនៃបារមីផ្សេងៗ ។

ខន្តិបារមី ខន្តិឧបបារមី ខន្តិបរមត្ថបារមី ដោយសេចក្តីអត់ធន់ ដល់ការធ្វើនូវសេចក្តីអន្តរាយនៃវត្ថុនោះៗ គឺឧបករណ៍បុត្រភរិយា អវយវៈ និងជីវិត ។

សច្ចបារមី សច្ចឧបបារមី សច្ចបរមត្ថបារមី ដោយការមិនលះបង់នូវសច្ចៈ ព្រោះហេតុវត្ថុទាំង ៣ យ៉ាង នោះៗឯង ។

អធិដ្ឋានបារមី ឧបបារមី និងបរមត្ថបារមី ដោយការអធិដ្ឋានមិនញាប់ញ័រ សូម្បីក្នុងគ្រាដែលវត្ថុទាំង ៣ ប្រភេទនោះ មានឧបករណ៍និងបុត្រភរិយាជាដើម ដល់នូវ

សេចក្តីវិនាសទៅ ដោយឃើញថាបារមី មានទានបារមីជាដើម រមែងបរិសុទ្ធដោយអំណាចអធិដ្ឋានមិនកម្រើក ។

មេត្តាបារមី ឧបបារមី និងបរមត្ថបារមី ដោយការមិនលះបង់នូវមេត្តាក្នុងសត្វទាំងឡាយ សូម្បីបុគ្គលដែលចូលមកទម្លាយនូវឧបករណ៍ឬបុត្រភរិយា អវយវៈនិងជីវិតរបស់ខ្លួននោះឯង ។

ឧបេក្ខាបារមី ឧបបារមី និងបរមត្ថបារមី ដោយភាពនៃឧបេក្ខាក្នុងសត្វ និងសង្ខារទាំងឡាយ ទាំងដែលមាននូវឧបការៈ និងទាំងដែលធ្វើនូវសេចក្តីវិនាសដល់វត្ថុ ៣ យ៉ាងនោះៗឯង តាមដូចដែលបានពោលហើយ (វត្ថុ ៣ យ៉ាងគឺ ឧបករណ៍បុត្រភរិយាជាវត្ថុនៃបារមី អវយវៈជាវត្ថុនៃឧបបារមី ជីវិតជាវត្ថុនៃបរមត្ថបារមី) ។

គប្បីជ្រាបការចែកនូវបារមីទាំងនោះ ដោយប្រការដូច្នេះឯង ។



## គូគុណធម៌សម្រេចដោយគូបារមី

សេចក្តីសម្រេចនៃការធ្វើអំពើជាប្រយោជន៍ និងការមិនធ្វើនូវអំពើមិនជាប្រយោជន៍ ដល់សត្វទាំងឡាយ ដោយគូបារមី គឺទាន និងសីល ។

សេចក្តីសម្រេចនៃអលោភៈ និងអទោសៈ ដោយគូបារមី គឺទាន និងខន្តី ។

សេចក្តីសម្រេចនៃចាគៈ និងសុតៈ ដោយគូបារមី គឺទាន និងវីរិយៈ ។

សេចក្តីសម្រេចនៃការលះកាម និងលះទោសៈ ដោយគូបារមី គឺទាន និងឈាន (ឈានជាសភាវៈរបស់នេក្ខម្មៈ) ។

សេចក្តីសម្រេចនៃទានទាំង ២ (អាមិសទាននិងធម្មទាន) ដោយគូបារមី គឺទាន និងបញ្ញា ។

សេចក្តីសម្រេចនៃសេចក្តីបរិសុទ្ធទាំង ២ បានដល់

សេចក្តីបរិសុទ្ធនៃបយោគៈ (ការព្យាយាមធ្វើប្រយោជន៍)១ និងសេចក្តីបរិសុទ្ធនៃអាសយៈ (អធ្យាស្រ័យប្រណីត ) ១ ដោយគូបារមី គឺសីល និងខន្តី ។

សេចក្តីសម្រេចនៃភាវនាទាំង ២ បានដល់សមថ-ភាវនា ១ និងវិបស្សនាភាវនា ១ ដោយគូបារមី គឺសីល និងវីរិយៈ ។

សេចក្តីសម្រេចនៃការលះភាពទ្រុស្តសីល និងលះភាពជ្រប់ងប់ក្នុងកាម ក្នុងអបាយមុខ ដោយគូបារមីគឺសីល និងឈាន ។

សេចក្តីសម្រេចនៃទានទាំង ២ បានដល់ អភយ-ទាន ១ និងធម្មទាន ១ ដោយគូបារមី គឺសីល និងបញ្ញា ។

សេចក្តីសម្រេចនៃសេចក្តីអត់ធន់ និងការមិនមានអំណាចកោងកាច ដោយគូបារមី គឺខន្តី និងវីរិយៈ ។

សេចក្តីសម្រេចនៃអនុរោធ (ការអនុគ្រោះ ការយល់ព្រមតាម ) និងការមិនមាននូវវិរោធ (កំហឹង កំហុស ការស្អប់ ជម្លោះ...) ដោយគូបារមី គឺខន្តី និងឈាន ។



សេចក្តីសម្រេចនៃការទ្រាំបាន និងបដិវេធក្នុងសុញ្ញតា (ការចាក់ធ្លុះក្នុងសង្ខារ និងព្រះនិព្វានដែលសូន្យចាកខ្លួន និងសូន្យចាកវត្ថុជារបស់ខ្លួនជាដើម ) ដោយគូបារមី គឺខន្តី និងបញ្ញា ។

សេចក្តីសម្រេចនៃបគ្គាហៈ (ការផ្គងនូវសេចក្តីព្យាយាម ) និងអវិក្ខេប (ការមិនរវើរវាយ ) ដោយគូបារមី គឺ វីរិយៈ និងឈាន ។

# ឧបាយឱ្យសម្រេច

ការសន្សំនូវបុញ្ញាទិសម្ភារទាំងអស់ ដើម្បីសម្មា-សម្ពោធិញ្ញាណ ដោយមិនធ្វើឱ្យខ្វះខាត ។ ការធ្វើដោយសេចក្តីគោរពក្នុងសម្មាសម្ពោធិញ្ញាណនោះ ដោយការអើ-ពើ និងដោយការរាប់អានដ៏ក្រៃលែង ។ ការធ្វើនូវសេចក្តីព្យាយាមឱ្យជាប់តគ្នា មានព្យាយាមជាលំដាប់ និងរហូតគ្រប់ពេលក្នុងរវាងនៃការឱ្យទានជាដើមដល់ទីបំផុត ។

ព្រះមហាសត្វ បដិបត្តិដើម្បីត្រាស់ដឹង បានបង្អោនខ្លួនប្រគល់ជីវិតថ្វាយដល់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ដើម្បីសម្មាសម្ពោធិញ្ញាណជាមុនសិនថា «ខ្ញុំព្រះអង្គសូមបង្អោនថ្វាយនូវអត្តភាពនេះចំពោះព្រះអង្គជាព្រះសម្មាសម្ពុទ្ធ» រួចហើយព្រះមហាសត្វ ប្រកាសលះបង់នូវរបស់ដែលហួង-ហែងថា « របស់ឯណានីមួយ ដែលជារបស់ប្រើប្រាស់ប្រចាំជីវិត បានមកជារបស់ខ្ញុំព្រះអង្គ របស់ទាំងអស់នោះ



កាលបើមានអ្នកសូម ខ្ញុំព្រះអង្គនឹងឱ្យ ខ្ញុំព្រះអង្គគប្បីបរិភោគ នូវរបស់ដែលសល់អំពីការឱ្យដល់យាចកទាំង-នោះប៉ុណ្ណោះ » ។

កាលដែលព្រះមហាបុរស តាំងចិត្តយ៉ាងនេះហើយក៏បានបរិច្ចាគទ្រព្យ មានដៃលាងស្អាត ត្រេកអរក្នុងការលះបង់ ផ្ចង់ស្មារតីក្នុងការចែកចាយ រមែងឱ្យទានដោយការគិតថា តពីនេះទៅ យើងនឹងមានចិត្តត្រេកអរក្នុងទានដ៏យ៉ាងក្រៃលែង ។

ព្រះមហាបុរស កាលដែលទេយ្យធម៌មានតិច និងមានការខ្វះខាត រមែងពិចារណាថា កាលមុនព្រោះយើងមិនចូលចិត្តក្នុងការឱ្យទាន ទើបឥឡូវយើងមានការខ្វះខាតព្រោះហេតុនោះ ពេលនេះទោះជាយើងត្រូវលំបាកយ៉ាងណាក៏ដោយ ទោះជាទេយ្យធម៌តិចតួចក៏ដោយ សៅហ្មងក៏ដោយ យើងត្រូវឱ្យទានទាល់តែបាន យើងនឹងសម្រេចនូវទានបារមីរហូតដល់ទីបំផុត ។

ព្រះមហាសត្វ កាលបើមានចិត្តមិនប្រាថ្នានឹងឱ្យ

ទានកើតឡើង ព្រោះស្តាយទេយ្យធម៌ រមែងដាស់តឿនខ្លួនឯងថា ម្នាលសប្បុរស អ្នកប្រាថ្នានូវសម្មាសម្ពោធិញ្ញាណ ជាញាណដ៏យ៉ាងខ្ពង់ខ្ពស់ ប្រសើរជាងរបស់ទាំងពួង មិនមែនទេឬ ព្រោះហេតុដូច្នោះ អ្នកគួរឱ្យនូវទេយ្យធម៌ ដែលអ្នកពេញចិត្តដ៏ក្រៃលែងនោះ ដើម្បីសម្មាសម្ពោធិញ្ញាណតែម្យ៉ាង ។ រួចហើយព្រះមហាសត្វក៏បានបរិច្ចាគលះបង់ត្រេកអរក្នុងការឱ្យ ។

ព្រះមហាសត្វ កាលឱ្យទាន រមែងឃើញការអស់ទៅនូវទេយ្យធម៌ក្នុងកាលណា រមែងពិចារណាថា សភាពរបស់ភោគៈទាំងឡាយ គឺយ៉ាងនេះឯង រមែងមានការអស់ទៅ សាបសូន្យទៅជាធម្មតា ម្យ៉ាងទៀត ព្រោះយើងមិនបានឱ្យទានដូចនេះពីមុនមក ទើបភោគៈទាំងឡាយប្រាកដនូវភាពអស់ទៅយ៉ាងនេះ ។ ឥឡូវនេះ យើងគប្បីឱ្យទានដោយទេយ្យធម៌ តិចក៏ដោយ ច្រើនក៏ដោយ យើងនឹងសម្រេចឱ្យដល់ទីបំផុតនៃទានបារមីតទៅ ។

ម្យ៉ាងទៀត ការប្រគល់ខ្លួនថ្វាយចំពោះព្រះសម្មា-



សម្ពុទ្ធទាំងឡាយ របស់ព្រះមហាសត្វនោះ ជាឧបាយឱ្យបារមីទាំងពួងសម្រេចដោយប្រពៃ ។ ពិតណាស់ ព្រះមហាបុរស ប្រគល់ខ្លួនថ្វាយចំពោះព្រះសម្មាសម្ពុទ្ធទាំង-ឡាយ ហើយឋិតនៅក្នុងសេចក្តីព្យាយាម ដើម្បីភាពសម្បូណ៌នៃពោធិសម្ភារ គឺការសន្សំនូវបារមី ដើម្បីបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គហ្នឹងឯង ។ កាលលះបង់នូវឧបករណ៍ជាដើម ដែលសម្រាប់ធ្វើឱ្យរាងកាយបានសុខ ក៏ដល់នូវការលំបាកក្នុងបច្ចុប្បន្ន ទ្រាំបានដោយលំបាកក្តី ការវិនាសទៅនូវកម្លាំងកាយ ដែលនឹងអាចបាត់បង់ជីវិតក្តី ព្រះមហាបុរសទោះជាដឹងថា ត្រូវលំបាកអត់ឃ្លាន រហូតដល់ត្រូវបាត់បង់ជីវិត ក៏នៅតែបង្អោនទេយ្យធម៌ចូលទៅដល់សត្វទាំងឡាយ ដោយមិនញាប់ញ័រមិនដល់នូវការប្រែប្រួលចិត្តសូម្បីតែបន្តិច ជាអ្នកមាននូវអធិដ្ឋានមាំមួនក្នុងការបំពេញកុសលដោយពិត ព្រោះហេតុតែបានបរិច្ចាគនូវអត្តភាពនេះ ដល់ព្រះសម្មាសម្ពុទ្ធស្រេចហើយ ។ ការប្រគល់កាយថ្វាយជីវិតយ៉ាងនេះ ក៏ជា

ឧបាយឱ្យបារមីទាំងអស់បានសម្រេច ដោយប្រពៃ តាមន័យនៃការឱ្យទាន ដូចដែលបានពោលហើយ ដោយប្រការដូច្នេះឯង ។

ម្យ៉ាងវិញទៀត ដោយសង្ខេប បុគ្គលអ្នកសន្សំនូវបុញ្ញាភិនីហារ រមែងមានការកាត់បន្ថយឱ្យមានការខ្សោយចុះ នូវការជំពាក់ទាក់ទិននឹងខ្លួនឯង តែត្រូវមានការជាប់ជំពាក់ទាក់ទិននឹងអ្នកដទៃ ចម្រើនឡើង នេះជាឧបាយឱ្យបារមីទាំងនោះសម្រេចបាន ។ ពិតណាស់ ព្រោះដើម្បីសម្រេចនូវសម្មាសម្ពោធិញ្ញាណ ការជំពាក់ទាក់ទិននឹងខ្លួនរបស់ព្រះមហាសត្វ ដែលជាបុគ្គលអ្នកធ្វើនូវមហាបណិធានទុកហើយ រមែងសាបរលាបខ្សោយចុះ ពោលគឺជាបុគ្គលមិនជាប់នៅក្នុងសង្ខារធម៌ទាំងពួង ព្រោះបានកំណត់ដឹងដោយបញ្ញានូវសង្ខារធម៌ទាំងពួងនោះៗ មានការអស់ទៅសូន្យទៅ គួរឱ្យនឿយណាយ ។ ឯការជាប់ជំពាក់ក្នុងសត្វទាំងឡាយដទៃពីខ្លួន ដោយអំណាចនៃមេត្តា និងករុណា រមែងចម្រើនឡើងដល់ព្រះមហាបុរស ដែលជា



អ្នកឃើញនូវសព្វសត្វដូចបុត្រជាទីស្រឡាញ់ មានព្រះទ័យពេញពោរដោយមហាករុណា ។

ព្រះមហាបុរស បានធ្វើនូវធម៌ដែលជាបដិបក្ខចំពោះពោធិសម្ភារ មានមច្ឆរិយៈសេចក្ដីកំណាញ់ជាដើមឱ្យឆ្ងាយសែនឆ្ងាយ ដោយចម្រើននូវសង្គហធម៌ សង្គ្រោះនូវពពួកជនក្នុងសង្គហវត្ថុ ៤ យ៉ាង គឺទាន ១ បិយវាចា (សម្ដីពីរោះគួរឱ្យចូលចិត្ត) ១ អត្ថចរិយា ( ការប្រព្រឹត្តជាប្រយោជន៍ ) ១ និងសមានត្តតា (ការមានខ្លួនស្មើចុងស្មើដើម រួមអង្គុយ រួមបរិភោគជាដើម ) ១ ។

ជាការពិតណាស់ មហាករុណា និងមហាបញ្ញារបស់ព្រះមហាសត្វទាំងឡាយ ប្រដាប់ដោយទាន រីឯទានប្រដាប់ដោយបិយវាចា ចំណែកបិយវាចាប្រដាប់ដោយអត្ថចរិយា ហើយអត្ថចរិយាក៏ប្រដាប់ដោយសមានត្តតាដែលជាការមិនប្រកាន់ខ្លួន ( ប្រដាប់គឺធ្វើឱ្យល្អប្រសើរ ) ។

ការបដិបត្តិដោយសេចក្ដីសង្គ្រោះ ចំពោះជនទាំងឡាយ ជាការធ្វើនូវអធិដ្ឋានធម៌ទាំង ៤ ឱ្យបរិបូណ៌

និងចម្រើនក្រៃលែងឡើង សម្រេចដល់ព្រះមហាសត្វ រហូតដល់ព្រះអង្គបានជាព្រះសម្មាសម្ពុទ្ធ ។ ក្នុងសេចក្តីនេះគប្បីជ្រាបថា ទាន ជាភាពសម្បូណ៌ និងជាការចម្រើននូវចាគាធិដ្ឋាន របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ។ បិយ-វាចា ជាភាពសម្បូណ៌ និងជាការចម្រើននូវសច្ចាធិដ្ឋាន ។ អត្ថចរិយា ជាភាពសម្បូណ៌ និងជាការចម្រើននូវបញ្ញា-ធិដ្ឋាន ។ សមានត្តតា ជាភាពសម្បូណ៌ និងជាការចម្រើននូវឧបសមាធិដ្ឋាន ។

នៅក្នុងអដ្ឋកថារតនសូត្រ សម្តែងអំពីពុទ្ធរតនៈ **វរោ** គឺព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ប្រសើរ ព្រោះធ្វើឱ្យបរិបូណ៌នូវឧបសមាធិដ្ឋាន ។ **វរញ្ញូ** ព្រះអង្គទ្រង់ជ្រាបដឹងនូវធម៌ដ៏ប្រសើរ គឺព្រះនិព្វាន ព្រោះធ្វើឱ្យបរិបូណ៌នូវបញ្ញាធិដ្ឋាន ។ **វរទោ** ព្រះអង្គទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ព្រោះធ្វើឱ្យបរិបូណ៌នូវចាគាធិដ្ឋាន ។ **វរាហរោ** ព្រះអង្គទ្រង់នាំមកនូវរបស់ដ៏ប្រសើរ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ។ ពិតណាស់ ព្រះដ៏មានព្រះភាគ



ទ្រង់បានបំពេញនូវបារមី ៣០ ចាប់ផ្តើមតាំងតែពីព្រះពុទ្ធព្រះនាម **ទីបង្ករ** មក ទ្រង់នាំមកនូវមគ្គដ៏ប្រសើរ ជាផ្លូវចាស់ ដែលព្រះសម្មាសម្ពុទ្ធទាំងឡាយ អង្គមុនៗ គ្រប់ៗព្រះអង្គទ្រង់យាងទៅហើយតាមផ្លូវនេះឯង ។ ឯការដែលព្រះអង្គទ្រង់នាំមកនូវរបស់ដ៏ប្រសើរ គឺ មគ្គសច្ចៈនោះព្រោះធ្វើឱ្យ បរិបូណ៌នូវសច្ចាធិដ្ឋាន ។

កាលព្រះមហាសត្វ សង្គ្រោះនូវសត្វលោកទាំង-ឡាយ ធ្វើសត្វលោកទាំងអស់ឱ្យជាអារម្មណ៍នៃករុណាបដិបត្តិក្នុងពោធិសម្ភារ សេចក្តីសម្រេចក្នុងបារមីទាំងពួងរមែងមាន ។ នេះព្រោះសមានត្តតា ភាពនៃការតម្កល់ខ្លួនស្មើ ដោយការមិនប្រកាន់ខ្លួន មានសុខទុក្ខស្មើក្នុងទីទាំងពួង បំណងឱ្យសត្វលោកឆ្លងផុតទុក្ខដូចព្រះអង្គដែរ ។

# រយៈពេលនៃការសម្រេច

លោកពោលក្នុងអដ្ឋកថា[១] ថា ដោយកំណត់យ៉ាងទាប ៤ អសង្ខេយ្យ និង ១ សែនមហាកប្ប ដោយកំណត់ជាកណ្តាល ៨ អសង្ខេយ្យ និង ១សែនមហាកប្ប ចំណែកយ៉ាងខ្ពស់កំណត់ ១៦ អសង្ខេយ្យនិង ១ សែនមហាកប្ប ។ ការផ្សេងគ្នាទាំងនេះ គប្បីជ្រាបដោយអំណាចដូចនេះគឺ **បញ្ញាធិក** ( ៤ អសង្ខេយ្យ ១ សែនមហាកប្ប ) **សទ្ធាធិក** ( ៨ អសង្ខេយ្យ ១ សែនមហាកប្ប ) **វីរិយាធិក** (១៦ អសង្ខេយ្យ ១ សែនមហាកប្ប ) តាមលំដាប់ដូច្នេះឯង ។

សទ្ធាទន់តែបញ្ញាខ្លាំងក្លា រមែងមានដល់បុគ្គលដែលជាបញ្ញាធិកទាំងឡាយ ។

បញ្ញាថ្នាក់កណ្តាល តែមានសទ្ធាច្រើន រមែងមានដល់បុគ្គលដែលជាសទ្ធាធិកទាំងឡាយ ។

១.អដ្ឋកថា សុត្តនិបាត ខគ្គវិសាណសូត្រ



សទ្ធាទន់ បញ្ញាក៏តិចតែមានសេចក្តីព្យាយាមច្រើន រមែងមានដល់បុគ្គលដែលជាវីរិយាធិកទាំងឡាយ ។

គប្បីជ្រាបថា ការបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ដោយអានុភាពនៃបញ្ញា ។

ព្រះពោធិសត្វ ៣ ពួកនេះ ផ្សេងគ្នាដោយកាលនៃការសន្សំ បុញ្ញាភិនីហារ គឺគិតត្រឹមពីពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់បានព្យាករមុនដំបូងមក មានការបំពេញបារមីដោយលំដាប់ រហូតបានសម្រេចនូវសម្មាសម្ពោធិញ្ញាណតាមកាលមានប្រភេទដូចដែលបានពោលហើយ ។

បើប្រភេទនៃកាលនោះៗ នៅមិនទាន់បរិបូណ៌គ្រប់គ្រាន់ទេ ព្រះមហាសត្វទាំងនោះ សូម្បីធ្វើមហាទានដូចជាទានរបស់ព្រះវេស្សន្តរ រាល់ៗថ្ងៃក្តី សន្សំនូវបារមីធម៌ទាំងពួងមានសីលជាដើមតាមសមគួរក្តី ធ្វើមហាបរិច្ចាគលះបង់នូវទ្រព្យ បុត្រ ភរិយា អវយវៈនិងជីវិតក្តី ញ៉ាំងនូវញាតត្ថចរិយា លោកត្ថចរិយា ពុទ្ធត្ថចរិយា ឱ្យដល់ទីបំផុតដ៏ក្រៃលែងក្តី ហើយក៏បានជាព្រះសម្មាសម្ពុទ្ធក្នុង

វវាងកាលកំណត់នោះ ហេតុនេះមិនជាឋានៈដែលអាចប្រព្រឹត្តទៅបានឡើយ ។ ព្រោះអ្វី ? ព្រោះញាណនៅមិនទាន់ចាស់ក្លា និងព្រោះពុទ្ធការកធម៌នៅមិនទាន់សម្រេច។

ពិតណាស់ សូម្បីព្យាយាមដោយឧស្សាហៈទាំងអស់យ៉ាងណា ក្នុងវវាងនោះ ក៏មិនអាចសម្រេចនូវសម្មាសម្ពោធិញ្ញាណ ដែលមានកំណត់កាលនោះបានឡើយ ។ ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ការពេញលេញបរិបូណ៌នៃបារមី រមែងសម្រេចដោយកាលវិសេសតាមដែលបានពោលហើយ ។



# អានិសង្សរបស់បារមី

ព្រះបរមពោធិសត្វ សម្បូណ៌ដោយអវយវៈទាំងពួង ត្រាច់ទៅក្នុងលោកអស់កាលជាអង្វែង រាប់បានរយកោដិកប្ប ជាបុគ្គលទៀងចំពោះពោធិញ្ញាណ ។ ព្រះបរមពោធិសត្វ រមែងមិនកើតក្នុងអវីចី និងលោកន្តរនរក ។ មិនកើតជានិជ្ឈាមតណ្ហិកប្រេត (ប្រេតមានភ្លើងដុតរោលរាល) ខុប្បិបាសិកប្រេត (ប្រេតមានតែការស្រេកឃ្លាន) កាលកញ្ចិកាប្រេត (ឈ្មោះប្រេតជាអសុរកាយមួយពួក) និងមិនកើតជាសត្វតូចជាងចាប ។ កាលដែលព្រះបរមពោធិសត្វ កើតក្នុងមនុស្សលោក គឺមិនកើតជាមនុស្សខ្វាក់ភ្នែក ត្រចៀកថ្លង់ និងជាមនុស្សគឡើយ ។ មិនជាមនុស្សឧភតោព្យញ្ជនក (មានភេទពីរ) មនុស្សបណ្ឌក (ខ្ទើយ) ព្រមទាំងមិនជាមនុស្សស្រីផងដែរ ។ ព្រះបរមពោធិសត្វមានគោចរបរិសុទ្ធក្នុងទីទាំងពួង ទៀងទាត់ចំពោះ

ពោធិញ្ញាណ ជឿកម្ម ជឿផលរបស់កម្ម មិនសេពនូវមិច្ឆាទិដ្ឋិ សូម្បីនៅក្នុងទេវលោក ក៏មិនដល់នូវភាពជាអ្នកភ្លេចខ្លួនឡើយ ។

ព្រះមហាសត្វ តែងឱនទៅក្នុងនេក្ខម្មៈ មិនជំពាក់ចិត្តក្នុងភពតូចនិងភពធំ រមែងប្រព្រឹត្តនូវលោកត្ថចរិយា (ការប្រព្រឹត្តដើម្បីប្រយោជន៍ដល់សត្វលោក ) ដោយការបំពេញបារមីទាំងពួង ។

សេចក្ដីអស្ចារ្យមិនធ្លាប់មាន ១៦ យ៉ាង[១] :

១.ជាធម្មតានៃព្រះបរមពោធិសត្វ ច្យុតចាកឋានតុសិត ទ្រង់មានសតិសម្បជញ្ញៈចុះកាន់ផ្ទៃនៃព្រះមាតា (ក្នុងជាតិចុងក្រោយ ) ។

២.ក្នុងកាលដែលព្រះបរមពោធិសត្វ ច្យុតចាកឋានតុសិត ចុះកាន់ផ្ទៃនៃព្រះមាតា គ្រានោះ ពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបានក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ... ។ លោកធាតុទាំងមួយហ្មឺន

---

១.បិដកលេខ ១៦ មហាបទានសូត្រ និងអដ្ឋកថា ។



កក្រើក រំពើកញ្ជាប់ញ័រ ទាំងពន្លឺដ៏ភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោក កន្លងនូវទេវានុភាពនៃទេវតាទាំងឡាយ ។

៣.ក្នុងកាលដែលព្រះបរមពោធិសត្វ ឋិតក្នុងផ្ទៃនៃព្រះមាតា មានទេវបុត្រ ៤ អង្គ តែងចូលទៅរក្សាក្នុងទិសទាំង ៤ ដោយគិតថា កុំឱ្យមនុស្ស និងអមនុស្សណានីមួយបៀតបៀនព្រះបរមពោធិសត្វ និងព្រះមាតានៃព្រះបរម-ពោធិសត្វនោះបានឡើយ ។

៤.ក្នុងកាលដែលព្រះបរមពោធិសត្វ ឋិតនៅក្នុងផ្ទៃនៃព្រះមាតា ព្រះមាតានៃព្រះបរមពោធិសត្វ មិនឋិតនៅជិតបាទមូលនៃអ្នកដទៃ ហើយសមាទាននូវសីលឡើយ ទ្រង់គង់ប្រថាប់លើអាសនៈដ៏ស្មើ គ្រាន់តែពិចារណាសីលដែលសមាទានហើយប៉ុណ្ណោះ ។ ជាអ្នកវៀរចាកបាណា-តិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ។

៥.ក្នុងកាលដែលព្រះបរមពោធិសត្វ ឋិតក្នុងផ្ទៃនៃ

ព្រះមាតា គឺព្រះមាតានៃព្រះបរមពោធិសត្វ មិនមានព្រះទ័យប្រកបដោយកាមគុណក្នុងបុរសទាំងឡាយ សូម្បីតែបិតានៃព្រះបរមពោធិសត្វ ម្យ៉ាងទៀត ព្រះមាតានៃព្រះបរមពោធិសត្វ មិនមានបុរសណាមួយ មានចិត្តត្រេកអរប្រព្រឹត្តកន្លងបានឡើយ ។

៦-ក្នុងកាលដែលព្រះបរមពោធិសត្វ ឋិតក្នុងផ្ទៃនៃព្រះមាតា តែងបាននូវកាមគុណទាំង ៥ ជាប្រក្រតី ។ ព្រះមាតានៃព្រះបរមពោធិសត្វនោះ តែងស្កប់ស្កល់ប្រកបព្រមមានអ្នកផ្គាប់បម្រើដោយកាមគុណទាំង ៥ ។ ព្រះរាជាក្នុងនគរដទៃដោយជុំវិញ បានបញ្ជូននូវបណ្ណាការ ដោយមិនអាចកំណត់បរិមាណនូវលាភសក្ការ ដល់ព្រះបរម-ពោធិសត្វ និងព្រះមាតារបស់ព្រះបរមពោធិសត្វឡើយ ។

៧-ក្នុងកាលដែលព្រះបរមពោធិសត្វ ឋិតក្នុងផ្ទៃនៃព្រះមាតា អាពាធណាមួយ ក៏មិនបានកើតឡើង ដល់ព្រះមាតានៃព្រះបរមពោធិសត្វឡើយ ។ ព្រះមាតានៃព្រះ-បរមពោធិសត្វ មានតែសេចក្ដីសុខជាប្រក្រតី មានកាយ



មិនលំបាក ម្យ៉ាងទៀត ព្រះមាតានៃព្រះបរមពោធិសត្វតែងមើលឃើញ ព្រះបរមពោធិសត្វ ហាក់ដូចជាឋិតនៅក្រៅផ្ទៃ សព្វអវយវៈ ទាំងធំទាំងតូច មានឥន្ទ្រិយមិនថោកថយ ។

អាស្រ័យព្រះបារមី ដែលព្រះបរមពោធិសត្វបានបំពេញមក ទើបធ្វើឱ្យវត្ថុរូបនៃព្រះបរមពោធិសត្វបរិសុទ្ធកាលវត្ថុរូបបរិសុទ្ធ ព្រះលក្ខណៈ គឺព្រះឆវីដ៏ល្អិតក៏បានបង្កើតឡើង ព្រះតចោ គឺស្បែកនៃព្រះឧទររបស់ព្រះវរ-មាតា មិនអាចនឹងបិទបាំងនូវព្រះឆវីនោះបាន ។ ព្រោះហេតុនោះហើយ ទើបព្រះបរមពោធិសត្វគង់ដុសខាត់ចិត្តដោយសមាធិ បែរព្រះភក្ត្រមកខាងព្រះឧទរនៃព្រះវរមាតាប្រាកដរូបកាយព្រះអង្គដល់ព្រះមាតា ដូចអំបោះពណ៌ខៀវលឿង ក្រហម ស និងពណ៌លឿងទុំក្នុងកែវមណីដូច្នោះឯង ។

៨-ក្នុងកាលព្រះបរមពោធិសត្វ ទ្រង់ប្រសូតមកបាន ៧ ថ្ងៃ ព្រះមាតានៃព្រះបរមពោធិសត្វ តែងសោយ

ព្រះទិវង្គតទៅកើតនៅឋានតុសិត ។ ព្រះមាតានៃព្រះ-បរមពោធិសត្វ សោយព្រះទិវង្គតក្នុងចំណែកទី ៣ នៃមជ្ឈិមវ័យ ។

៩.ព្រះមាតានៃព្រះបរមពោធិសត្វ តែងទ្រង់គភ៌ព្រះបរមពោធិសត្វអស់ ១០ ខែគត់ ទើបបានប្រសូត ។

១០.ព្រះមាតានៃព្រះបរមពោធិសត្វ ទ្រង់ប្រថាប់ឈរប្រសូតព្រះបរមពោធិសត្វ ។ ព្រះបរមពោធិសត្វទ្រង់ប្រសូត ដូចព្រះធម្មកថិកចុះពីធម្មាសនៈ ឬដូចបុរសចុះពីជណ្ដើរ ដូច្នោះឯង ។

១១.ក្នុងកាលដែលព្រះបរមពោធិសត្វ ប្រសូតចាកផ្ទៃនៃព្រះមាតា ព្រះព្រហ្មជាព្រះខីណាស្រពនៃជាន់សុទ្ធា-វាស ជាអ្នកទទួលព្រះបរមពោធិសត្វមុនគេ បន្ទាប់មកមហាទេវរាជទាំង ៤ ទទួលបន្តពីព្រះព្រហ្ម បន្ទាប់មកទៀតទើបមនុស្សទាំងឡាយទទួលជាខាងក្រោយ ។

១២.ក្នុងកាលដែលព្រះបរមពោធិសត្វ ប្រសូតចាកផ្ទៃនៃព្រះមាតា ព្រះបរមពោធិសត្វមិនទាន់ចុះដល់ផែនដី



ផង មហាទេវរាជទាំង ៤ ក៏ទទួលព្រះអង្គ ឋិតនៅពីខាងមុខនៃព្រះមាតា ហើយពោលថា « បពិត្រព្រះនាងទេវី សូមព្រះនាងមានព្រះហឫទ័យរីករាយចុះ បុត្ររបស់ព្រះនាងជាអ្នកមានស័ក្តិធំ ទ្រង់កើតឡើងហើយ » ។

១៣.ក្នុងកាលដែលព្រះបរមពោធិសត្វ ប្រសូតចាកផ្ទៃនៃព្រះមាតា គឺល្អល្អះស្រស់បស់ យាងចេញមកមិនប្រឡាក់ដោយទឹកមន្ទិលអ្វី និងមិនប្រឡាក់ដោយឈាមជាដើមឡើយ គឺជាបុគ្គលស្អាតបរិសុទ្ធ ។

១៤.ក្នុងកាលដែលព្រះបរមពោធិសត្វ ប្រសូតចាកផ្ទៃនៃព្រះមាតា មានធារទឹក ២ ហូរចុះមកអំពីអាកាស ធារទឹក ១ ត្រជាក់ ធារទឹក ១ ក្ដៅ ធ្វើនូវការស្រោចស្រពដល់ព្រះបរមពោធិសត្វផង ព្រះមាតាផង ។

១៥.ក្នុងកាលដែលព្រះបរមពោធិសត្វ ប្រសូតមកមួយសន្ទុះ ទ្រង់ផុតពីដៃមនុស្សហើយ ទ្រង់ប្រតិស្ឋានឈរដោយព្រះបាទទាំងគូដ៏ស្មើ ទ្រង់សម្លឹងមើលទៅទិសបូព៌ាច្រើនពាន់ចក្រវាឡ បានប្រាកដឡើងដល់ចក្ខុរបស់ព្រះអង្គ

ពួកទេវតានាំគ្នាបូជាដោយគ្រឿងក្រអូបនិងផ្កាឈើជាដើម ហើយនាំគ្នាពោលថា « បពិត្រព្រះមហាបុរស ក្នុងលោកនេះ សូម្បីតែបុគ្គលឱ្យដូចព្រះអង្គក៏មិនមានឡើយ នឹងរកបុគ្គលឱ្យក្រៃលែងជាងព្រះអង្គដូចម្ដេចបាន » ។

ព្រះបរមពោធិសត្វទ្រង់សម្លឹងមើលទិសធំ ៤ ទិស តូច ៤ ទិសក្រោម និងទិសលើ ទ្រង់មិនឃើញបុគ្គលណាដូចព្រះអង្គ ទ្រង់កំណត់ថានេះជាទិសឧត្តរ ហើយទ្រង់បែរព្រះភក្ត្រទៅកាន់ទិសឧត្តរនោះ ទ្រង់យាងឈានទៅ ៧ ជំហាន ។ កាលដែលពពួកទេវតាកំពុងបាំងស្វេតច្ឆត្រថ្វាយ ក៏រមិលមើលនូវទិសទាំងពួងផង ទ្រង់ពោលនូវអាសភិវាចា គឺវាចាដ៏អង់អាចក្លាហាន ជាវាចាដ៏ឧត្ដមផងថា « យើងជាបុគ្គលខ្ពង់ខ្ពស់របស់លោក យើងជាបុគ្គលធំចម្បងបំផុតរបស់លោក យើងជាបុគ្គលប្រសើរបំផុតរបស់លោក នេះជាកំណើតចុងក្រោយបង្អស់របស់យើង ឥឡូវនេះ ភពថ្មីតពីនេះទៅទៀត មិនមាន ឡើយ » ។

នៅក្នុងសេចក្ដីអស្ចារ្យខាងលើនេះ គប្បីជ្រាបថា :



-ការប្រតិស្ឋានឈរលើផែនដី ដោយព្រះបាទទាំងគូដ៏ស្មើ ជាបុព្វនិមិត្តនៃការបាននូវឥទ្ធិបាទ ៤ ។

-ការបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ជាបុព្វនិមិត្តនៃការដែលព្រះអង្គ ទ្រង់យាងទៅគ្រប់គ្រងទូន្មានដល់មហាជន ។

-ទ្រង់យាង ៧ ជំហាន ជាបុព្វនិមិត្តនៃការបាននូវរតនៈ គឺពោជ្ឈង្គ ៧ ។

-ការកាន់ស្វេតច្ឆត្រទិព្វបាំងថ្វាយ ជាបុព្វនិមិត្តនៃការបានឆត្រដ៏ប្រសើរ គឺ វិមុត្តិ ។

-ការបានរាជកកុធភណ្ឌទាំង ៥ (ទេវតាមិនប្រាកដរូបកាន់គ្រឿងទាំងអស់នេះ) ជាបុព្វនិមិត្តនៃវិមុត្តិទាំង ៥។

-ការសម្លឹងរមិលមើលទិសទាំងពួង ជាបុព្វនិមិត្តនៃការបាននូវអនាវរណញ្ញាណ ។

-ការបន្លឺនូវអាសភិវាចា ជាបុព្វនិមិត្តនៃការប្រព្រឹត្តទៅនៃព្រះធម្មចក្កប្បវត្តនសូត្រ (បឋមទេសនា) ។

-ការបន្លឺសីហនាទថា « នេះជាជាតិចុងក្រោយ

របស់យើង » ជាបុព្វនិមិត្តនៃការបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ដោយប្រការដូច្នេះឯង ។

១៦.ក្នុងកាលដែលព្រះបរមពោធិសត្វ ប្រសូតចាកផ្ទៃនៃព្រះមាតា គ្រានោះពន្លឺភ្លឺស្វាងរកប្រមាណមិនបានកើតប្រាកដឡើង ដូចពេលដែលព្រះអង្គទ្រង់យាងចុះកាន់ព្រះគភ៌ ដូច្នោះដែរ ព្រមទាំងបុព្វនិមិត្តច្រើនទៀត ។

នៅក្នុងថ្ងៃដែលព្រះមហាបុរសប្រសូត[១] ក្រៅអំពីបុព្វនិមិត្តដែលបានសម្តែងហើយ នៅមានបុព្វនិមិត្ត ៣០ ដោយឡែកផ្សេងទៀតគឺ :

១.ហ្មឺនលោកធាតុញាប់ញ័រ ជាបុព្វនិមិត្តនៃការបានសព្វញ្ញុតញ្ញាណ របស់ព្រះមហាបុរសនោះ ។

២.ការប្រជុំក្នុងចក្រវាឡជាមួយគ្នានៃទេវតាទាំងឡាយ ជាបុព្វនិមិត្តនៃការប្រជុំដោយទំនងដូចគ្នា ក្នុងកាលដែលញ៉ាំងធម្មចក្កឱ្យប្រព្រឹត្តទៅ គឺជាការប្រជុំគ្នាទទួលព្រះធម៌ ។

---

១.អដ្ឋកថា មហាបទានសូត្រ



៣.ការទទួលព្រះពោធិសត្វដោយពួកទេវតាមុន ជាបុព្វនិមិត្តនៃការបានរូបាវចរជ្ឈាន ៤ (ឈានចតុក្កន័យ)។

៤.ការទទួលព្រះបរមពោធិសត្វ ដោយពួកមនុស្សជាក្រោយ ជាបុព្វនិមិត្តនៃការបានអរូបជ្ឈាន ៤ ។

៥.ពិណលេងបញ្ចេញសំឡេង ដោយការផ្ទាត់ខ្សែខ្លួនឯង ជាបុព្វនិមិត្តនៃការបានអនុបុព្វវិហារធម៌ ៩ (ចូលរូបជ្ឈាន ៤ អរូបជ្ឈាន ៤ ហើយចូលនិរោធសមាបត្តិ) ។

៦.ស្គរលាន់ឡើងដោយខ្លួនឯង ជាបុព្វនិមិត្តនៃការបានឮសំឡេងធម្មភេរីដែលជាស្គរជ័យដ៏ធំក្រៃលែង ។

៧.ប៉មនិងទីឃុំឃាំងជាដើមត្រូវបាក់ ជាបុព្វនិមិត្តនៃការកាត់ដាច់នូវអស្មិមានះ ។

៨.មហាជនស្ងប់ចាករោគ ជាបុព្វនិមិត្តនៃការបានអរិយសច្ចៈ ៤ ។

៩.មនុស្សភ្នែកខ្វាក់ពីកំណើត បានឃើញរូប ជាបុព្វនិមិត្តនៃការបានទិព្វចក្ខុ ។

១០.មនុស្សត្រចៀកថ្លង់បានឮសំឡេង ជាបុព្វនិមិត្ត

នៃការបានទិព្វសោត ។

១១.មនុស្សពិការ ទៅជាមានកម្លាំងរឹងប៉ឹង ជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ។

១២.មនុស្សគពីកំណើត ស្រាប់តែនិយាយបាន ជាបុព្វនិមិត្តនៃការបានសតិប្បដ្ឋាន ៤ ។

១៣.ទូកសំពៅទៅប្រទេសដទៃ ដល់កំពង់ដោយស្រួល ជាបុព្វនិមិត្តនៃការបានបដិសម្ភិទា ៤ ។

១៤.រតនវត្ថុបញ្ចេញរស្មីដ៏ក្រៃលែង ដោយខ្លួនឯង ជាបុព្វនិមិត្តនៃពន្លឺព្រះធម៌ ដែលព្រះបរមពោធិសត្វនឹងបានត្រាស់ ហើយប្រកាសដល់សត្វលោក ។

១៥.បុគ្គលមានពៀរនឹងគ្នា ទៅជាមានមេត្តាចិត្តដល់គ្នាវិញ ជាបុព្វនិមិត្តនៃការបានព្រហ្មវិហារធម៌ ៤ ។

១៦.ភ្លើងក្នុងអវីចីរលត់ ជាបុព្វនិមិត្តនៃការរលត់ភ្លើង ១១ កង (ភ្លើងរាគៈ ទោសៈ មោហៈ ជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងឧបាយាស គឺសេចក្តីចង្អៀតចង្អល់ ) ។



១៧.លោកន្តរនរកភ្លឺស្វាង ជាបុព្វនិមិត្តនៃការកម្ចាត់ភាពងងឹតគឺអវិជ្ជា ដោយពន្លឺនៃញាណ ។

១៨.ទឹកទន្លេមិនហូរ ជាបុព្វនិមិត្តនៃការបានវេសារជ្ជញ្ញាណ ៤[១] ។

១៩.មហាសមុទ្រមានរសផ្អែម ជាបុព្វនិមិត្តនៃការមានរសតែមួយនៃព្រះធម៌ ៨៤.០០០ ព្រះធម្មក្ខន្ធ គឺវិមុត្តិរស ដែលជារសនៃព្រះពុទ្ធសាសនា ។

២០.ការដែលខ្យល់មិនបក់ ជាបុព្វនិមិត្តនៃការទម្លាយទិដ្ឋិ ៦២[២] ។

២១.បក្សីទាំងឡាយចុះមកដើរនៅលើដី ជាបុព្វនិមិត្តនៃការស្តាប់ឱវាទហើយ បានដល់នូវសរណៈស្មើជីវិតរបស់មហាជន ។

២២.ការដែលព្រះចន្ទភ្លឺស្វាងស្រឡះ ភ្លឺច្បាស់ខ្លាំង (ក្នុងយប់នោះ គឺយប់ថ្ងៃពេញបូណ៌មី ) ជាបុព្វនិមិត្តនៃភាព

---

១.មានក្នុងមហាសីហនាទសូត្រ បិដកលេខ ២០ ទំព័រ ២៧១ ។

២.ទិដ្ឋិ ៦២ មានក្នុងព្រហ្មជាលសូត្រ បិដកលេខ ១៤ ។

ស្អាតស្រស់បស់ របស់មនុស្សយ៉ាងច្រើន ( ជាអ្នកស្អាតដោយគុណធម៌ ) ។

២៣_ការដែលព្រះអាទិត្យប្រាសចាកកម្តៅ ទាំងត្រជាក់ក៏មិនបានបៀតបៀន អាកាសធាតុជាទីសប្បាយ ជាបុព្វនិមិត្តនៃសេចក្តីសុខផ្លូវកាយ ផ្លូវចិត្ត (នៃអ្នកដែលបានទទួលព្រះធម៌ ) ។

២៤_ការដែលពួកទេវតា នៅនឹងទ្វារវិមាន ហើយរីករាយដោយការទះដៃ គ្រវីទង់ជាដើម ជាបុព្វនិមិត្តនៃការបន្លឺឧទានរបស់ព្រះមហាបុរស ដែលបានដល់នូវភាពជាព្រះសម្មាសម្ពុទ្ធហើយ (ឧទាន ៨២ សូត្រក្នុងបិដកលេខ ៥២ ) ។

២៥_ការដែលភ្លៀងធ្លាក់ទាំង ៤ ទិស ជាបុព្វនិមិត្តនៃការធ្លាក់ចុះនៃភ្លៀងគឺព្រះធម៌ទេសនា ។

២៦_ក្នុងពេលនោះ មិនមានការឃ្លានដល់សត្វទាំងឡាយ ជាបុព្វនិមិត្តនៃការបានទឹកអម្រឹត គឺកាយគតាសតិ ។



២៧_ការដែលមិនមាននូវសេចក្តីស្រេកទឹក ចំពោះសត្វទាំងឡាយ ជាបុព្វនិមិត្តនៃការបានចូលដល់វិមុត្តិសុខ។

២៨_ការដែលទ្វារបង្អួចបើកឯង ជាបុព្វនិមិត្តនៃការបើកទ្វារ គឺអរិយមគ្គមានអង្គ ៨ ។

២៩_ការដែលដើមឈើចេញផ្លែផ្កា ជាបុព្វនិមិត្តនៃផ្ការីក គឺ វិមុត្តិ និងច្រើនទៅដោយភាពនៃបុគ្គលដែលបាននូវសាមញ្ញផល (ផលរបស់សមណភាព មានសោតាបត្តិផលជាដើម ) ។

៣០_ការដែលហ្មឺនលោកធាតុ មានទង់ផ្កាឈើដូចគ្នា ជាបុព្វនិមិត្តនៃការដែលបុគ្គលមានទង់ផ្កាគឺអរិយៈ ។

អានិសង្សដទៃទៀតឯណា មានសភាពដែលបានសម្តែងទុកក្នុងព្រះជាតក និងពុទ្ធវង្សជាដើមនោះៗ មានជាអាទិ៍យ៉ាងនេះថា « ភាពជាអ្នកជំនាញក្នុងកម្មជាដើម ជាការបានសម្រេច តាមបំណងរបស់ព្រះបរមពោធិសត្វទាំងឡាយ » ទាំងអស់នោះ ជាអានិសង្សរបស់បារមី ។

ម្យ៉ាងទៀត គប្បីជ្រាបអានិសង្សមានគូនៃគុណធម៌

គឺអលោភៈ និងអទោសៈជាដើម មានប្រភេទតាមដែលបានសម្តែងទុកហើយ ។

នៅមានទៀត ព្រះបរមពោធិសត្វ ស្មើដោយបិតារបស់សព្វសត្វ ចាប់តាំងតែពីបានសន្សំអភិនីហារ ដើម្បីស្វែងរកប្រយោជន៍មក ជាបុគ្គលគួរដល់ទក្ខិណា គួរគោរពលើកតម្កើង និងជាស្រែបុណ្យដ៏ក្រៃលែង ព្រោះប្រកបដោយគុណវិសេស ។ ព្រះបរមពោធិសត្វ ជាទីស្រឡាញ់របស់មនុស្ស អមនុស្សដ៏ច្រើន ទេវតាឃុំគ្រងរក្សា សត្វកាចជាដើមគ្របសង្កត់បៀតបៀនមិនបាន ព្រោះព្រះអង្គមានសន្តានព្រះហឫទ័យអប់រំដោយមេត្តាករុណា។ ព្រះមហាពោធិសត្វ កើតក្នុងពួកសត្វណាៗ រមែងគ្របសង្កត់សត្វដទៃ ក្នុងពួកសត្វនោះៗ ដោយវណ្ណៈ យស សុខ ពលៈ និងភាពជាអធិបតីដ៏ក្រៃលែង ព្រោះប្រកបដោយបុណ្យដ៏វិសេស ។

ព្រះមហាពោធិសត្វ ជាបុគ្គលមានអាពាធតិច មានរោគតិច ។ សទ្ធារបស់ព្រះបរមពោធិសត្វនោះ បរិសុទ្ធ



ដោយល្អ ទាំងវីរិយៈ សតិ សមាធិ បញ្ញា ក៏បរិសុទ្ធដោយល្អផងដែរ ។ កិលេសស្រាលស្តើង មានការក្រវល់ក្រវាយតិច សេចក្តីក្តៅក្រហាយក៏តិច ជាបុគ្គលទូន្មានបានដោយងាយ ព្រោះកិលេសស្រាលស្តើង ។ ជាបុគ្គលមានសេចក្តីគោរព អត់ធន់ស្ងប់ស្ងៀម ទន់ភ្លន់ ឆ្លាតក្នុងបដិសណ្ឋារៈ។

ក្នុងភពនោះៗ តាមសមគួរ ព្រះបរមពោធិសត្វ មិនក្រោធ មិនចងនូវសេចក្តីក្រោធ មិនរមិលគុណ មិនវាយឫក មិនកំណាញ់ មិនច្រណែន មិនអួតអាង មិនមាយា មិនរឹងត្អឹង មិនប្រកាន់ខ្លួន មិនមើលងាយ និងមិនប្រមាទ ។

ព្រះបរមពោធិសត្វ ដល់នូវសេចក្តីសង្វេគមានប្រមាណដ៏ក្រៃលែង ព្រោះហេតុដូច្នោះ គប្បីជ្រាបថាគុណវិសេសទាំងនោះ មានភាពជាទក្ខិណេយ្យបុគ្គល និងស្មើដោយបិតាជាដើមរបស់សត្វទាំងឡាយ គឺជាអានិសង្សដែលព្រះមហាបុរសបានក្នុងភពនោះៗ តាមសមគួរ ។

ស្ងួម្បីគុណសម្បត្តិទាំងអស់នេះទៀត គឺ **អាយុ**-

**សម្បទា រូបសម្បទា កុលសម្បទា ឥស្សរិយសម្បទា** និង **អាទេយ្យវចនតា** ព្រមទាំង**មហានុភាវតា** គប្បីជ្រាបថា ជាអានិសង្សនៃបារមីទាំងឡាយ របស់ព្រះមហាបុរស ។ ក្នុងគុណសម្បត្តិទាំងអស់នេះគឺ :

**អាយុសម្បទា** បានដល់ការមានអាយុវែង ការរស់នៅយូរក្នុងភពនោះៗ ដែលបានកើត ហើយញុំាងនូវកុសលសម្បទា ក្នុងរវាងនៃការរស់នៅនោះឱ្យដល់ទីបំផុត គឺមានការសន្សំទុកនូវកុសលបានច្រើន ។

**រូបសម្បទា** បានដល់ការដែលមានរូបល្អស្អាត គួរមើល គួរជ្រះថ្លា ជាបុគ្គលនាំមកនូវសេចក្ដីជ្រះថ្លា គួរជាទីលើកតម្កើងនៃសត្វទាំងឡាយ ដែលកាន់យករូបជាប្រមាណ ដោយរូបសម្បទានោះ ។

**កុលសម្បទា** បានដល់ការកើតក្នុងត្រកូលខ្ពស់ គួរចូលទៅរក គួរចូលទៅអង្គុយជិត ។ ដោយអំណាចនៃកុលសម្បទា បានធ្វើឱ្យអ្នកដែលស្រវឹងនឹងជាតិត្រកូលរបស់ខ្លួនជាដើមនោះត្រូវអស់ព្យសន៍ ថយចុះនូវសេចក្ដីស្រវឹង។



**ឥស្សរិយសម្បទា** បានដល់ ភាពជាបុគ្គលមានសម្បត្តិច្រើន មានស័ក្តិធំ និងមាននូវបរិវារច្រើន ។ ជាអ្នកអាចសង្គ្រោះដល់បុគ្គលដែលគួរសង្គ្រោះ និងគ្របសង្កត់នូវបុគ្គលដែលគួរគ្របសង្កត់ដោយធម៌ អាស្រ័យឥស្សរិយសម្បទានោះឯង ។

**អាទេយ្យវចនតា** បានដល់ភាពនៃបុគ្គលដែលមានសម្ដីគួរឱ្យជឿ គួរឱ្យកាន់យក គួរយកជាប្រមាណ គឺគួររាប់ គួរយកជាការពិតនៃសត្វទាំងឡាយបាន ព្រោះពាក្យសន្យា ឬពាក្យទូន្មានរបស់ព្រះបរមពោធិសត្វនោះឯង មិនត្រឡប់ត្រឡិនឡើយ ។

**មហានុភាវតា** បានដល់អានុភាពធំ ច្រើន ប្រសើរ សម្បើម ខ្លាំង ... ។ អ្នកដទៃគ្របសង្កត់មិនបាន ប៉ុន្តែខ្លួនឯងគ្របសង្កត់អ្នកដទៃបានដោយពិត គឺគ្របសង្កត់ដោយធម៌ ស្មោះស្មើដោយគុណតាមសេចក្ដីពិត តាមដែលខ្លួនឯងមាននូវអានុភាពគឺ តេជះ អំណាច គុណ បុណ្យ កម្លាំង ឫទ្ធិ ... ដ៏ធំ ខ្លាំង ឬច្រើនជាដើមនោះឯង ។

គប្បីជ្រាបថា គុណសម្បត្តិដ៏វិសេស មានអាយុ-សម្បទាជាដើម ទាំងអស់នោះ ជាអានិសង្សនៃបារមីទាំងឡាយរបស់ព្រះមហាបុរស និងជាហេតុនៃសេចក្ដីចម្រើនរបស់បុញ្ញសម្ភារដែលរកប្រមាណមិនបាន ព្រម-ទាំង ជាហេតុនៃការចម្រើនរុងរោចន៍នូវញាណសម្បទា ។



## ផលរបស់បារមី

ផលនៃបារមីទាំងឡាយ បើពោលដោយសង្ខេប ឬសរុប បានដល់ភាពជាព្រះសម្មាសម្ពុទ្ធ ជាព្រះបរមសាស្ដាដ៏អស្ចារ្យក្រៃលែងហ្នឹងឯង ។

បើពោលដោយពិស្ដារ ព្រះសិរីធម្មកាយដ៏ត្រចះត្រចង់បំផុត តាំងឡើងដោយគុណរកប្រមាណមិនបាន ទាំងសិរីសម្បត្តិរបស់រូបកាយក៏រុងរឿងអស្ចារ្យ ដែលមានមហាបុរិសលក្ខណៈ ៣២ ប្រការ អនុព្យញ្ជន ៨០ ឆព្វណ្ណ-រង្សីជាដើម ។

ដោយឡែកផ្សេងទៀត គឺអធិដ្ឋានធម៌ ៤ ទស-ពលញ្ញាណ (កម្លាំងញាណ ១០ ) វេសារជ្ជញ្ញាណ ៤ អសាធារណញ្ញាណ ៦ ។ល។

សូម្បីព្រះសម្មាសម្ពុទ្ធ ក៏មិនអាចនឹងសរសើរនូវព្រះពុទ្ធគុណទាំងឡាយ ឱ្យអស់ទៅបានដែរ ។ ទោះជាត្រូវប្រើពេលសរសើរគិតជាកប្បក៏ដោយ កប្បអស់ទៅក្នុង

រវាងនោះដ៏ច្រើន តែព្រះគុណរបស់ព្រះតថាគត នៅសរសើរមិនទាន់អស់ឡើយ ។

### ព្រះសម្មាសម្ពុទ្ធជាបុគ្គលឯកក្នុងលោក

-បុគ្គលឯក កើតឡើងក្នុងលោក ដើម្បីជាគុណ ដើម្បីសេចក្តីសុខ ដើម្បីអនុគ្រោះ ដើម្បីប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ ។

-ជាបុគ្គលរកបានដោយក្រក្នុងលោក ។

-ជាអច្ឆរិយមនុស្ស គឺមនុស្សដ៏អស្ចារ្យ ។

-កាលកិរិយានៃបុគ្គលឯក គឺកាលកិរិយានៃព្រះ-តថាគត ជាទីសោកស្តាយនៃជនច្រើន ។

-ជាបុគ្គលមិនមានអ្នកដទៃប្រៀបផ្ទឹមបាន ។

-បុគ្គលឯក កើតឡើងក្នុងលោក ជាការកើតប្រាកដនៃចក្ខុដ៏ប្រសើរ ពន្លឺដ៏ប្រសើរ រស្មីដ៏ប្រសើរ... ។



## ធម្មនិយាម ៣០ របស់ព្រះពុទ្ធ គ្រប់ព្រះអង្គ

សូម ក្រាប បង្គំ ប្រណម្យ វន្ទា ឆ្ពោះ ព្រះ ភគវា ពុទ្ធា បាន ត្រាស់ ធម្មនិយាម ទំនៀម ល្អ ល្អះ សាមសិបមុខច្បាស់ ខ្ញុំសូមពណ៌នា។

**មួយ** រញ្ជួយភព ជាតិគ្រប់ចុងក្រោយ បារមី នាំ ឱ្យ ដឹង ពេល វេលា ទ្រង់ យាង កាន់ ផ្ទៃ ស្មារតី ល្អ ជា dågxøÜn RKb;RKa kñúgKP’ mata ។

**ពីរ** គឺ ព្រះភក្ត្រ វរលក្ខណ៍ ក្នុងគភ៌ ស្ទឹង ស្មាធិ៍ ក្នុង ធម៌ បវរ កាយា

**ចី** ឥរិយាបថ នៃ ព្រះ មាតា ពេលគ្រប់ មាសា សាស្តា ចាកផ្ទៃ mata RTg; Qr xus RsI déT ប្រសូត បុត្រ ថ្ងៃ ហប្ញទ័យ ជ្រះថ្លា ។ **ម្ភួន** sYn]Tüan TIzan RbsUt ក្នុងព្រៃ រហូត ឈើ ស្រូត ចេញ ផ្កា ទេវតា និង មនុស្ស ថ្វាយសាធុការ ចក្រវាឡ បញ្ញា ខ្ទរ័ខ្ទារ អ៊ូអរ ។ **ឆ្នាំ** RBHRbsUt cuHRsÚt yagQan ប្រាំពីរ ជំហាន ឆ្ពោះ ទិស ឧត្តរ ត្រូតគ្រប់ ទិសថាន ក្លាហាន បវរ ទើបបាន បន្ត បន្លឺ សីហនាទ ។ **ឆ្នាំមួយ**



**ឆ្នាំពីរ** ធីរោ ផ្តាច់ប្តូរ ព្យាយាម ឥតមាន ទាក់ទាម ក្នុងនាម អ្នកបួស kMNt; evla minGac tichYs R)aMBIréf¶ena H nwg)an Rtas;dwg ។ **ឆ្នាំចី** mehsI Kg; esay )ayas ក្នុងថ្ងៃ បានត្រាស់ ទ្រង់ ច្បាស់ ទីពឹង បាយាសថាសមាស ថ្វាយព្រះថ្ងៃហ្នឹង ហៅបាយត្រាស់ដឹង បានបុណ្យមហិមា។ **ឆ្នាំម្ភួន** CYnP½BV RTg;RTab; s,ÚvPøaMg ក្លាយ ជា បល្ល័ង្ក គង់ តាំង ភាវនា នៅគល់

**ដប់មួយ** ជំនួយ ពីព្រះបារមី p©aj;mar GRbIy_ RBmTaMg esna ពុទ្ធប្បវត្តិ ត្រង់ នេះ អស្ចារ្យ បរិស័ទ ជ្រះថ្លា បាច ផ្កា អភិសេក ។

**ដប់ពីរ** munIGgÁ RTg;seRmcjaN ត្រៃវិជ្ជាមាន ទ្រង់ញាណ អនេក ពិសាខបុណ្ណមី កើតញាណ ប្លែកៗ ពេញធិញ្ញាណខ្ពស់ឯក កក្រើកធរណី។

**ដប់បី** kSRt éf Kg;kñúg mhazan វិមុត្តិ ក្សេម ក្សាន្ត អស់ ថាន ប្រាំពីរ សបាហ៍ ថានមួយ លើកស្ទួយ ស្ថានទី ចេតិយ ព្រះមុនី



**ដប់ប្រាំ** caMc,as; RTg;Rtas; Fmµcká \sibtn³ éRB miKTaya ថាន ត្រៃរតនៈ អាសាឡ្ហ បូជា ថ្ងៃព្រះភគវា ស្ថាបនា ព្រះសង្ឃ ។

**ដប់ប្រាំមួយ** RTg; Kg;Rtas; »vaT បាដិមោក្ខ ស្អាងស្អាត ឱវាទផ្លូវផង់ បេះដូង ព្រះធម៌ ពន្លឺ ចតុរង្គ ថ្ងៃនោះ ត្រូវត្រង់ មាឃបុណ្ណមី ។

**ដប់ប្រាំពីរ** ទ្រង់ គង់វត្ត ជេតពន ប្រោសដល់ មហាជន និរន្តរ៍ ប្រក្រតី ទ្រង់ យក អរុណ ជេតពន សួសþ eCtBn CínRsI GaRs½y

**ដប់ប្រាំបួន** RTg; Kg;zanRt½yRtigS ត្រិះ រិះ រំពឹង ថ្លឹង គុណ មាតា សម្តែង អភិធម្ម ស័ក្តិសម អស្ចារ្យ ថ្វាយ ព្រះ មាតា សុខា អមតៈ ។

**ម្ភៃ** គឺ RBHGgÁ RTg;cak eTvelak ស្តេចយាង ចុះមក ដែន សង្កស្សៈ មហាជន ច្រើនពិត យកចិត្ត ទុកដាក់ បូជា គារវៈ អចលចេតិយ ។

**ម្ភៃមួយ** គឺ RTg; Kg;kñúg smabtþi ព្រះញាណស្ងប់ស្ងាត់ លះកាត់លោកីយ៍ អរហត្តផល តម្កល់ ប្រក្រតl



**ម្ភៃបី** RTg; él vín½y GaCJa បញ្ញត្ត សិក្ខា តាម ការ ជ្រាប ជាក់ មានរឿង កើតមុន ខូចគុណ សាវក មានហេតុជាក់លាក់ ទើបដាក់វិន័យ។

**ម្ភៃបួន** អង្រួន ហឫទ័យ ករុណា ជាតក ទេសនា សាស្តា លកលៃ ដើមរឿង ជាហេតុ បង្កើត អត្ថន័យ CatkRbéB éltam ehtukarN_ ។

**ម្ភៃប្រាំ**ទ្រង់ប្រោស ដល់ពួកព្រះញាតិ អង្គព្រះលោកនាថ សម្តែងបាដិហារ្យ កម្ចាត់ មានះ ព្រះ ញាតិ វង្សា eTIbRtas; eTsna Km<Ir BuT§vgS ។

**ម្ភៃឆ្នាំពីរ** RTg; Kg; caM vsSa បើមាន នរណា និមន្ត ដោយល្អ ពេលចេញ វស្សា មុនយាង ចេញចរ RTg;ceRmInBr Rtas;laGñkena H . **ម្ភៃឆ្នាំបី** ទ្រង់ គង់យ៉ាង ហ្មត់ចត់ មុនភត្តក្រោយភត្ត គ្មានភ្លាត់ភ្លេចសោះ bMeBj BuT§kic© RKb;yam TaMgGs; ពុទ្ធកិច្ចសង្គ្រោះ មនុស្សនិងទេវតា។ **ម្ភៃឆ្នាំបួន** RTg; Kg; esay mMs³ kñúgéf¶



**អរហំ** រី ខ្ញុំ បង្គំ វន្ទា ឆ្ពោះ ព្រះ ភគវា ព្រះធម៌ ថ្លៃ ថ្លា ព្រមទាំង ព្រះសង្ឃ ផ្ទូរផង់ សីលា ចិន្ដា លំអុត ព្រះពុទ្ធ និយាម ។ សូមឱ្យ សព្វសត្វ បដិបត្តិ តាមធម៌ សាសនា បវរ ល្អដូច ព្រះនាម អរហំ សម្មា គ្មានការ ទាក់ទាម កិលេស រវាម រវាត សូន្យបង់ ។ សូមឱ្យ សាសនា សម្មា សម្ពុទ្ធ បរិសុទ្ធ មោះមុត រួមចិត្ត ទ្រទ្រង់ ឋិតថេរចិរកាល អភិបាលដោយសង្ឃ ព្រមព្រៀងស្មោះត្រង់ ផ្ចិតផ្ចង់សិក្ខា។ សូមមនុស្ស ទេវតា មានការ គោរព ទាំងថ្ងៃ ទាំងយប់ ក្នុងព្រះសាសនា សូមបាន សម្រេច ដូចក្តី ប្រាថ្នា Gs;nUv tNða Tukca ch;ehag ..

## ខ្លឹមសារខ្លីៗ

១-បង្ហាត់សត្វបាន ចាត់ថាពូកែ

បង្ហាត់មនុស្សបាន ចាត់ថាប្រសើរ ។

ឯការបង្ហាត់ខ្លួនឯងបាន គឺពូកែផង ប្រសើរផង និង បានទ្រូវទីពឹងដ៏ពិតប្រាកដផង ។

២-សូម្បីមិនជាអ្នកមានទ្រព្យច្រើន ប៉ុន្តែបើបានធ្វើប្រយោជន៍ឱ្យដល់សង្គម ស្លាប់ទៅនៅមានមនុស្សគេលើកតម្កើង ។ បើមានទ្រព្យច្រើនជាសេដ្ឋីក៏ដោយ តែមិនបានធ្វើប្រយោជន៍អ្វីឱ្យដល់សង្គមទេ លុះដល់ស្លាប់ទៅនោះ គេនឹងសើចចំអក ។



៣-បើយើងបានធ្វើសេចក្ដីល្អ ហើយយើងបាននឹករលឹកនៅក្នុងចិត្តថា «យើងជាមនុស្សល្អ យើងមានសេចក្ដីសុខ» ដូច្នេះ យើងនឹងបានសេចក្ដីសុខពិតៗក្នុងជីវិត ។

៤-គ្រប់គ្នាបានសេចក្ដីសុខពីអ្នកដទៃ ប៉ុន្តែដែលជាពិសេសនោះ គឺសេចក្ដីសុខក្នុងអំពើល្អរបស់ខ្លួនឯង ។

៥-យើងជ្រើសរើសកន្លែងកើតមិនបាន ជ្រើសរើសកន្លែងស្លាប់ក៏មិនបាន ព្រមទាំងអ្វីៗច្រើនទៀត ដូចជាភរិយា ស្វាមី កូន និងសម្ភារៈផ្សេងៗ កម្រនឹងបានល្អដោយសព្វគ្រប់ណាស់ ប៉ុន្តែ យើងអាចជ្រើសរើសយកអំពើល្អបាន ដែលអំពើល្អនោះមានតែល្អម្យ៉ាងប៉ុណ្ណោះ ។

៦-ចូរមានមេត្តាដល់មនុស្សទូទៅ ប៉ុន្តែ មិនត្រូវទុកចិត្តចំពោះមនុស្សទាំងអស់គ្នាឡើយ ត្រូវមានបញ្ញាគូគ្នាជាមួយនឹងមេត្តាផង ត្រូវចេះស្គាល់មនុស្សឱ្យបានល្អផង ។

៧_ការខុសភ្លាត់ ជាបទសិក្សាដ៏មានតម្លៃ និងជាមេរៀនល្អបំផុត ។

៨_ពាក្យល្អបវរភាសិត បានស្ដាប់ ឬបានអានហើយគិត កឱ្យកើតបញ្ញា នាំមកនូវការដោះស្រាយបញ្ហាជីវិតបាន ដូច្នេះ ពិតជាសំខាន់ដ៏ក្រៃលែង ។

៩_ពូកែ តែចរិតនិស្ស័យមិនថ្លៃថ្នូរ ចរិយាមិនល្អ គឺជាមនុស្សក្រកល្យាណមិត្ត ។

មិនពូកែ តែចរិតនិស្ស័យថ្លៃថ្នូរ ចរិយាល្អ គឺជាមនុស្សមានមិត្តល្អតែមិនសូវសម្បូណ៌ ។

ពូកែថែមទាំងចរិតនិស្ស័យថ្លៃថ្នូរចរិយាល្អទៀតផងគឺជាមនុស្សសម្បូណ៌កល្យាណមិត្តព្រមទាំងលាភយស...។

១០_មនុស្សមិនព្យាយាមនឹងក្រនូវអ្វីៗគ្រប់យ៉ាង។

មនុស្សមិនប្រយ័ត្ន នឹងក្រដូចគ្នាដែរ ។



មនុស្សមិនចេះគ្រប់ ទោះជាមានសម្បត្តិច្រើនប៉ុនណា ក្នុងចិត្តពិតជាក្រ ប៉ុន្តែបើមនុស្សមិនចេះគ្រប់នឹងសេចក្ដីល្អវិញ អាចសម្រេចបានជាព្រះសម្មាសម្ពុទ្ធ ។

១១_មនុស្សស្រវឹង មនុស្សឆ្កួត នាំមកនូវអន្តរាយតិចជាងមនុស្សពាល ។

គេចពីមនុស្សពាល ត្រូវគេចឱ្យឆ្ងាយ ហើយត្រូវចេះឧបាយក្នុងការគេចទៀតផង ។

១២_ ជក់បារី ធ្វើបានដោយងាយ

បរិភោគស្រា ធ្វើបានដោយងាយ

ឈប់ជក់បារី ធ្វើបានដោយក្រ

ឈប់បរិភោគស្រា ធ្វើបានដោយក្រ ។

អ្វីៗ ដែលធ្វើបានដោយងាយ អ្នកណាៗ ក៏ធ្វើបានដែរ ប៉ុន្តែអ្វីៗ ដែលធ្វើបានដោយក្រ ដោយលំបាក ប្រសិនបើអ្នកណាធ្វើបាន គឺជាកំពូលមនុស្ស ។

**១៣**-បង្គាប់ខ្លួនឯង កុំឱ្យអង្គុយខ្វែងជើង ឬគង អន្ទាក់ខ្លា ឬញាក់ជើង មិនទាំងបានផង តើនឹងអាចយក ឈ្នះគ្រឿងញៀនញ៉ាម ចំណង់លោកិយអ្វីៗផ្សេងៗទៀត បានយ៉ាងម៉េចទៅ ។

ល្មើសគុណបុព្វការី មិនឃ្លាតខ្ចីធ្វើការងារ
ប្រឹងប្រែងតែឈ្លោះគ្នា ពិតវងាកំព្រាសព្វ ។
កំព្រាទាំងគុណធម៌ ចិត្តញាប់ញ័រសែនអភ័ព្វ
ខ្វះញាតិខ្វះទាំងទ្រព្យ កំព្រាសព្វព្រោះស្អប់ធម៌។

**១៤**-អនាគតដែលល្អ ព្រោះបង្គាប់ខ្លួនឯងបាន ។
អនាគតដែលអាក្រក់ ព្រោះចាញ់ខ្លួនឯង ។

កេរ្តិ៍ឈ្មោះល្អ ខំតស៊ូ សាងច្រើនឆ្នាំ
ឈ្មោះប្រេះស្រាំ ប្រាំនាទី ដូចលីសព ។



**១៥**-នៅពេលថ្ងៃ មានរឿងដែលធ្វើឱ្យចិត្តអរ ចិត្ត អន់ មានឡើងមានចុះ ញាប់ញ័រតាមលោកធម៌ រាប់ដង មិនអស់ លុះដល់ពេលយប់ មុនទទួលទានដំណេក មាន អ្នកប្រាប់ថាឱ្យយល់សប្តិល្អ ។ មិនថាសុបិនល្អ ឬអាក្រក់ ឡើយ វាគឺជាចិត្តដែលត្រេកអរ ឬ អាក់អន់ជាដើមក្នុងការ យល់សប្តិហ្នឹងឯង ។

**១៦**-មនុស្សខ្ជិល ដេកចាំឱកាសល្អ ឯមនុស្សមាន ព្យាយាមវិញ ដើរចេញទៅរកឱកាសល្អដោយខ្លួនឯង ។ តាមពិត ឱកាសល្អ មិនបានចូលមករកមនុស្សខ្ជិលឡើយ។

**១៧**-សេចក្តីសុខចំពោះមុខ ជាសេចក្តីសុខសែនខ្លី រីឯសេចក្តីសុខក្នុងអនាគត ជាសេចក្តីសុខយូរអង្វែង ។ កុំ វង្វេងក្នុងសេចក្តីសុខចំពោះមុខ បណ្តោយឱ្យសេចក្តីសុខ ក្នុងអនាគតសាបសូន្យ ។

១៨. រឹងរឹតតែនិយាយដល់សេចក្តីអាក្រក់របស់អ្នកដទៃ សេចក្តីល្អរបស់ខ្លួនឯង គឺកាន់តែថយចុះ នេះព្រោះមកពីយើងនិយាយដោយចិត្តអកុសល ។

១៩. ជួយមិនឱ្យគេដួល ល្អជាងជួយលើក ។
ជួយឱ្យគេចេះគិត ល្អជាងជួយគិតឱ្យគេ ។

២០. ពេលសុខយើងញញឹមទទួលសេចក្តីសុខដល់ពេលទុក្ខយើងក៏ញញឹមបានដែរ គឺញញឹមបណ្តេញសេចក្តីទុក្ខចេញពីដួងចិត្ត ។

២១. យើងចូលចិត្តនិយាយថា « ចាស់ហើយត្រូវចូលវត្ត » ហាក់ដូចជាព្រះពុទ្ធសាសនាសម្រាប់តែបដិបត្តិឱ្យបានសម្រេចនូវប្រយោជន៍ ក្នុងបរលោកក្រោយពីស្លាប់ប៉ុណ្ណោះ ។



យើងមិនចូលចិត្តនិយាយថា « នៅក្មេងៗត្រូវចូលវត្ត » ផងទេ ។ ក្រែងបញ្ហាក្នុងសង្គមសព្វថ្ងៃ មួយផ្នែកធំមកពីក្មេងៗមិនចូលវត្តហ្នឹងឯងហើយ មិនមែនទេឬ ។

២២. ទឹកមន្តដែលស័ក្តិសិទ្ធិពិតប្រាកដ គឺញើសរបស់យើងហ្នឹងឯង ។

ស្រោចទឹកមន្ត គឺ ស្រោចញើសរាល់ថ្ងៃដោយការហាត់ប្រាណ ឬដោយសេចក្តីព្យាយាមធ្វើការងារ រមែងកាត់បន្ថយនូវរោគផ្សេងៗ និងមិនខ្វះខាតនូវទ្រព្យសម្បត្តិ។

២៣. គេថាយក្សគួរឱ្យខ្លាច សាកសពគួរឱ្យរង្កៀសប៉ុន្តែពេលយើងក្រោធ មុខមាត់អាក្រក់ សំឡេងខ្លាំងហើយញ័រ ញ័រទាំងដងខ្លួនដៃជើងទាំងអស់ ពិតជាគួរឱ្យខ្លាចជាង រង្កៀសជាង ។

**២៤**-សត្វប្រចៀចស្រែកយំចេចចាច មិនពីរោះ មនុស្សគេយកដៃបិទត្រចៀក រីឯសត្វតាវៅយំគ្រលួច លើចុងឈើខ្ពស់ សំឡេងពីរោះគេចង់ស្តាប់។ នេះជាធម្មជាតិម្យ៉ាងដែលមនុស្សយើងគួរសិក្សា ពិចារណា ដើម្បីរៀបចំជីវិតឱ្យប្រសើរឡើង ។

**២៥**-បើសេចក្តីសម្រេច កើតមកពីការបន់ស្រន់បួងសួង ពិតមែននោះ ក្នុងលោកនេះ មិនមានអ្នកណាប្រឡងធ្លាក់ មិនមានអ្នកណាឈឺ មិនមានអ្នកណាក្រ មិនមានអ្នកណាខកចិត្ត...ឡើយ ។

**២៦**-ព្រះរាជាឬប្រជារាស្ត្រ សេដ្ឋីឬអ្នកសូមទាន ស្លាប់ហើយសុទ្ធតែរលួយស្អុយដូចគ្នា ប៉ុន្តែ បុគ្គលមានគុណធម៌ កេរ្តិ៍ឈ្មោះរមែងក្រអូបសាយទៅក្នុងពពួកជន សូម្បីរាងកាយស្អុយរលួយទៅហើយក៏ដោយ ។



**២៧**-ផ្លែមិនខាំម្ចាស់អ្នកចិញ្ចឹមទេ ប៉ុន្តែ ញាតិអាក្រក់ មិត្តអាក្រក់ សូម្បីមានការចិញ្ចឹមបីបាច់ ឬទំនុកបម្រុងដោយល្អយ៉ាងណា ក៏នៅអាចខាំអ្នកចិញ្ចឹមនោះៗ ដូច្នេះត្រូវប្រយ័ត្នផងដែរ ។

**២៨**-ចូរធ្វើឧបសគ្គ ឱ្យក្លាយជាជណ្តើរ សម្រាប់ឡើងទៅរកអនាគតដ៏ខ្ពង់ខ្ពស់ ។

**២៩**-បើបាននូវអំណាច ធ្វើជាអ្នកធំលើមនុស្ស ត្រូវកុំអង្គុយលើក្បាលមនុស្ស តែត្រូវអង្គុយលើចិត្តរបស់គេឱ្យបាន ពោលគឺគ្រប់គ្រងចូលឱ្យដល់ចិត្តនៃមនុស្សគ្រប់គ្នា ទើបការគ្រប់គ្រងបានសម្រេច ។

ទាន ១ បិយវាចា ១ អត្ថចរិយា[១] ១ និង សមានត្តតា ១ ធម៌ទាំង ៤ នេះ សម្រាប់អ្នកគ្រប់គ្រងលើមនុស្សទាំងឡាយ ចូលដល់ក្នុងចិត្តអ្នកដទៃ ។

---

១-អត្ថចរិយា គឺការប្រព្រឹត្តជាប្រយោជន៍ដែលប្រកបដោយបញ្ញា ។

៣០~ ពាក្យនិន្ទាអាចធ្វើឱ្យខូចកម្លាំងចិត្ត

ពាក្យសរសើរអាចធ្វើឱ្យវង្វេងភ្លេចខ្លួន ។

ប៉ុន្តែ ពាក្យជាបទពិចារណា ដោយបំណងដ៏ល្អ រមែងធ្វើឱ្យមានកម្លាំងចិត្ត និងមិនឱ្យវង្វេងភ្លេចខ្លួន ។

៣១~ទោះបីខូចអ្វីៗក៏ដោយ ខូចមិត្ត ខូចបុគ្គលជាទីស្រឡាញ់ ខូចទ្រព្យ ខូចឈ្មោះ ។ល។ កុំឱ្យតែខូចកម្លាំងចិត្ត ព្រោះការខូចកម្លាំងចិត្ត ស្មើគ្នានឹងការខូចអ្វីៗគ្រប់យ៉ាង អ្វីៗក៏ក្លាយទៅជាអត់ន័យសម្រាប់ជីវិត លទ្ធផលចុងក្រោយ គឺ វិកលចរិត ឬធ្វើអត្តឃាត ។

៣២~មានពាក្យនិយាយប្រៀបធៀបថា « ពេលវេលាដូចបក្សីដែលមានស្លាបហើរបាន » ។

សូម្បីពេលវេលានឹងកន្លងទៅដូចជាមានស្លាបហើរក៏ដោយ ក៏យើងអាចបង្គាប់ប្រាប់ផ្លូវឱ្យហើរទៅបានដែរ គឺទៅតាមផ្លូវប្រមាទ ឬផ្លូវមិនប្រមាទ ។



៣៣~ជីវិតដែលមានឈ្មោះល្បី ជីវិតដែលមាំមួនដោយទ្រព្យ ជីវិតដែលបានជួបប្រសព្វនូវសេចក្តីសម្រេច អាចមិនមែនជីវិតដែលជាសុខ ។

៣៤~ពាក្យនិយាយថា « ស្លាប់ហើយយកអ្វីទៅមិនបាន » អ្នកណាៗក៏និយាយបានដែរ ព្រោះនិយាយតាមភ្នែកឃើញ និយាយរួចហើយ នៅតែលោភៈ ទោសៈ មោហៈដដែលដូចដើម ។ ប៉ុន្តែបើនិយាយតាមដែលចិត្តបានឃើញថា « ធម៌ទាំងឡាយ មិនគួរប្រកាន់ថាជារបស់មាំមួន » លោភៈ ទោសៈ មោហៈនឹងត្រូវថយចុះ ។

៣៥~មិនចំពោះតែកិច្ចការណាមួយ ឬកំពុងស្ថិតនៅក្នុងស្ថានការណ៍បែបណានោះឡើយ អ្នកដែលជួយយើងបានល្អជាទីបំផុត គឺខ្លួនយើងហ្នឹងឯង ។

អ្នកទីមួយ លើកស្ទួយយើង ឱ្យថ្កើងថ្កាន
ឬដែលបាន ច្រានទម្លាក់ ដល់អវិចី
គឺខ្លួនឯង ដែលប្រឹងប្រែង ក្នុងលោកីយ៍
ភ្លាត់ស្មារតី ធ្លាក់អវិចី ព្រោះខ្លួនដែរ ។

**៣៦**~មនុស្សទូទៅច្រើនតែយល់ថា «ការបរិភោគដ៏ប្រសើរ» គឺបរិភោគរបស់ថ្លៃ បរិភោគរឿយៗ បរិភោគច្រើន និងបរិភោគខ្ជះខ្ជាយជាដើម ។ តាមការពិត ការបរិភោគបែបនេះ មិនជាការប្រសើរឡើយ វាបែរត្រឡប់មកជាមានបញ្ហាសុខភាព និងបញ្ហាសេដ្ឋកិច្ចតាមក្រោយទៅវិញទេ ។

**៣៧**~បរិភោគអាហារ ដែលមានប្រយោជន៍ គឺអាហារមិនថ្លៃ ងាយនឹងរលាយ អាហារជាទីសប្បាយមិនទាស់នឹងសុខភាព ហើយបរិភោគតែល្មមប្រមាណដល់រាងកាយដែលត្រូវការ មិនបរិភោគច្រើនហួសទៅតាមតែចិត្តចង់ យ៉ាងនេះហៅថា បរិភោគដោយបញ្ញា ។



**៣៨**~ទុក្ខព្រោះមិនមានអ្វីបរិភោគ ជាមួយនឹងទុក្ខព្រោះបរិភោគច្រើនពេក វាគឺជាទុក្ខដូចតែគ្នា ។

**៣៩**~ការភ័យខ្លាច វាមានកំណើតមក សម្រាប់សព្វសត្វទាំងអស់ ប៉ុន្តែសេចក្តីក្លាហាន សម្រេចបានដោយការហ្វឹកហាត់ ។

**៤០**~ការគិត ការនិយាយ និងការធ្វើរបស់យើង គឺជាអ្នកសាងអនាគតឱ្យយើង ។

**៤១**~បើបង្ខាប់ ឬប្រដៅខ្លួនឯងមិនបានទេ រឿងអាក្រក់ៗ នឹងតាមមក ។

ត្រូវប្រយ័ត្នរឿង ៤ មុខ :

-ក្រព្រោះបរិភោគ
-ស្មោកគ្រោកព្រោះយស
-ខូចឈ្មោះព្រោះកាម
-រហេមរហាមព្រោះឈ្លោះគ្នា ។

៤ មុខល្អប្រសើរ ៖

-បរិភោគឱ្យរស់

-ប្រើយសសង្គ្រោះជន

-កាមគុណត្រូវសង្រួម

-យល់ព្រមឈប់ឈ្លោះ ។

៤២-ការដែលមានជីវិតរស់នៅ បើគ្រាន់តែដើម្បីខ្លួនឯងទេនោះ សូម្បីនឹងមានអាយុវែងទៅប៉ុនណា ក៏ប្រាសចាកប្រយោជន៍ដែរ ។ ប៉ុន្តែបើបុគ្គលធ្វើប្រយោជន៍របស់ខ្លួនឱ្យវិនាសព្រោះតែអ្នកដទៃ ជីវិតពិតជាអត់ទីពឹង។

៤៣-ការដែលមានជីវិតរស់នៅ ដោយសេចក្តីក្លាហានក្នុងកុសល ដោយស្មារតី និងដោយការប្រព្រឹត្តធម៌ដ៏ប្រសើរ រមែងបានជាប្រយោជន៍ទាំងដល់ខ្លួនឯង និងទាំងដល់អ្នកដទៃ គឺជាជីវិតដែលប្រសើរជាងទេវតាក្នុងឋានតាវត្តិង្សទៅទៀត ។



៤៤-ការហ្វឹកហាត់ឱ្យអភ័យរាល់ថ្ងៃ ទាំងផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត នេះពិតជាយុទ្ធនាការកម្ចាត់ទោសៈ សាងមេត្តាដ៏ប្រសើរ ។

៤៥-មិនមានសេចក្តីសុខណាដែលជាសុខពិត ដូចជាការអស់ទុក្ខឡើយ ។

៤៦-ធ្វើជាតម្រូតត្រូតខ្លួនឯងបាន គឺជាការកាត់បន្ថយសេចក្តីទុក្ខពីខ្លួនឯង រហូតដល់អស់ ។ ការអស់ទុក្ខជាសុខពិតប្រាកដ ។

៤៧- ខ្វះទ្រព្យអាចរស់បាន

ខ្វះញាតិអាចរស់បាន

ខ្វះអវយវៈអាចរស់បាន

ខ្វះសតិឈ្មោះថាស្លាប់ហើយ ។

**៤៨**~មនុស្សវិកលចរិត មនុស្សឡប់ៗ សត្វតិរច្ឆាន និងមនុស្សដែលកំពុងប្រព្រឹត្តអាក្រក់គ្រប់បែបយ៉ាង ទាំង-អស់នេះវាជារឿងតែមួយគត់ គឺខ្វះសតិ ។

កាលបើគិតយល់ហើយថា សតិមានតម្លៃប៉ុនណា សម្រាប់ជីវិតនោះ គួរអប់រំសតិ រក្សាសតិ កុំបំផ្លាញសតិខ្លួនឯងដោយគ្រឿងស្រវឹងផ្សេងៗ ថែមទាំងត្រូវប្រយ័ត្នឱ្យណាស់ចំពោះកាមារម្មណ៍ ។

**៤៩**~ ម្ហូបអាហារឆ្ងាញ់តែលេបមិនចូល
ពូកទន់គ្រែថ្លៃតែដេកមិនលក់
បន្ទប់ម៉ាស៊ីនត្រជាក់តែនៅក្តៅចិត្ត ។

ព្រោះហេតុតែមិនបានយកចិត្តទុកដាក់ ក្នុងការថែរក្សាចិត្តរបស់ខ្លួនឯង ដូច្នេះទើបដេកមិនលក់ បក់មិនល្ហើយ បាយមិននឹក ទឹកមិនស្រេក ។

កាលបើដូច្នេះ មនុស្សយើងមិនត្រូវបោះបង់ចិត្តរបស់ខ្លួនឯងចោលឡើយ ត្រូវតែថែរក្សាដោយហ្មត់ចត់ ។



**៥០**~ដើម្បីជីវិតរស់ក្នុងកាម ត្រូវរហេមរហាមក្នុងការងារ ចិញ្ចឹមជីវិតស៊ីងតែមិនរស់ ថែមទាំងមានរោគា... អត់ទានអត់សីល អត់ភាវនា កំព្រាសប្បុរស រស់អត់ន័យ ។

**៥១**~ពិតជាស្រឡាញ់ខ្លួន ខំពួនធ្វើបាប លួចឆក់អាក្រក់ក្រៃ កេរ្តិ៍ឈ្មោះឆ្អេះឆ្អាប ស្រាស្រីបារីគ្រឿងញៀនដើរបង្កភ័យ... ។

នេះជាការស្រឡាញ់ខ្លួន ឬជាទាសៈនៃខ្លួនឯង ? ឬក៏ជាសត្រូវនឹងខ្លួនឯង ?

**៥២**~បម្រើព្រះរតនត្រ័យវិញ កុំចាំបាច់បម្រើខ្លួនឯង ។ បម្រើខ្លួនឯងមិនផុតពីសេចក្តីទុក្ខឡើយ បម្រើព្រះរតនត្រ័យ ទើបផុតចាកទុក្ខ ។

**៥៣**~បូជាថ្វាយព្រះរតនត្រ័យវិញ ព្រោះព្រះរតន-ត្រ័យប្រសើរជាងយើងអសង្ខេយ្យដង គឺរាប់ដងមិនអស់។

៥៤. យើងថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ គឺជាការបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធប្រសើរជាងយើង។ នេះជាការលះបង់នូវសេចក្តីប្រកាន់ខ្លួនមួយផ្នែក តទៅនឹងមិនមានអ្វីសម្រាប់ខ្លួនឯងឡើយ មិនជាទាសៈនៃខ្លួនឯង មិនកង្វល់នឹងខ្លួនឯង មិនចាំបាច់ផ្គាប់ផ្គុនខ្លួនឯងអ្វីទាំងអស់ មានតែការអស់ទៅនៃទុក្ខប៉ុណ្ណោះ នេះជាអានិសង្សចុងក្រោយនៃការថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ។

៥៥. រូបកាយ ដូចផ្ទះសំណាក់ សុខនិងទុក្ខប្រៀបដូចភ្ញៀវ ។ សេចក្តីទុក្ខមិនបាននៅជាប្រចាំឡើយ មកហើយក៏ទៅ សេចក្តីសុខក៏ដូចគ្នា មកហើយក៏ទៅ ។ រូបកាយមិនជាទីហួងហែងនៃសុខទុក្ខ ឯសុខទុក្ខក៏មិនជាទីហួងហែងនៃរូបកាយដែរ ។

ជីវិតគ្រប់គ្នាជាការដើរផ្លូវ
មិនអាចទៀងនៅក្នុងភពណា។



បានដើរមកហើយលះបង់ជាតា
ភពដូចសាលាសំណាក់មួយគ្រា ។
គ្រប់គ្នាមកជុំសាលាសំណាក់
មិនត្រូវជំពាក់មាសប្រាក់ត្រឹមហា
រឹតតែមិនត្រូវឈ្លោះទាស់ទែងគ្នា
នេះជាវេលាត្រូវមានវិចារណ៍ ។
ជីវិតគ្រប់គ្នាជាការដើរផ្លូវ
លំបាកពេកក្រូវមិនដឹងទៅណា
គ្មានទីបំផុតតាមផ្លូវមោហា
ផ្លូវត្រៃសិក្ខាទើបដល់និព្វាន ។

៥៦. គិតខុស គិតថ្មី
និយាយខុស និយាយថ្មី
ធ្វើខុស ធ្វើថ្មី
ខុសហើយកែខៃ ខុសហើយចាំទុក
នឹងបានមិនខុស ។

៥៧-ថ្ងៃកូនកើត គឺជាថ្ងៃដែលម៉ែលំបាកផ្លូវកាយដ៏ខ្លាំងក្លា ។

ថ្ងៃកូនកើត គឺជាថ្ងៃដែលម៉ែជិតតែនឹងស្លាប់។ ប៉ុន្តែប្លែកមែនទែន ត្រង់ដែលកូនៗមកចាត់ពិធីកម្ម សប្បាយរីករាយ សម្រាប់ថ្ងៃកំណើតរបស់ខ្លួន ។

តាមពិត ថ្ងៃកំណើតគួរតែជាថ្ងៃនឹកម៉ែ ។

៥៨-មានប្រាក់ច្រើន នឹងទិញអ្វីក៏បាន ប៉ុន្តែទិញសេចក្តីសុខមិនបានឡើយ ទិញសុគតិក៏មិនបានដែរ ។

៥៩- មានរថយន្តល្អច្រើនគ្រឿង
មានផ្ទះច្រើនខ្នង
មានដីច្រើនកន្លែង
មានប្រាក់ច្រើនលានដុល្លារ ... ។

ប៉ុន្តែ បើខ្វះធម៌ក្នុងចិត្ត នឹងរកសេចក្តីសុខ បានដោយលំបាក ។



៦០-មនុស្សប្រមាទ មនុស្សទ្រុស្តសីល សូម្បីដល់ទៅថ្នាក់បៀមព្រះនឹងមាត់ ពាក់ព្រះនឹងក ក៏មិនអាចជួយខ្លួនឱ្យរួចពីសភាវៈអាក្រក់បានដែរ ។

៦១-ថ្ងៃនេះ នៅឱ្យចម្លើយខ្លួនឯងមិនបានផងថា តាំងតែពីក្មេងតូចមកបានធ្វើល្អអ្វីខ្លះ ចុះដល់ទៅថ្ងៃនោះយមរាជសាកសួរក្នុងឋាននរក ដែលជាកន្លែងសោយទុក្ខ នឹងបានអ្វីឆ្លើយតបទៅ ។

៦២- មានចំណេះផ្លូវលោកខ្ពង់ខ្ពស់
បានយសនិងបានទ្រព្យច្រើន ... ។
មិនមែនមានន័យថា បានសុខច្រើនឡើយ ។
អ្នកមានសេចក្តីសុខច្រើន គឺអ្នកមានទុក្ខតិច ។

អ្នកមានទុក្ខតិច គឺអ្នកដែលមានលោភៈ ទោសៈ មោហៈតិចហ្នឹងឯង ។

**៦៣**. ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ជាការប្រាប់ឱ្យដឹងថា ថ្ងៃនោះចូលមកកាន់តែជិតហើយ ។ ថ្ងៃនោះ គឺជាថ្ងៃ សូន្យអស់រលីង ដេកម្នាក់ឯង អត់គូ អត់ញាតិ អត់មិត្ត កន្លែងដេករឹងចង្អៀតណែន ។

ទ្រព្យសម្បត្តិមានច្រើនសន្ធឹកសន្ធាប់ តែយកទៅមិនបាន មានតែសម្លៀកបំពាក់មួយសម្រាប់ដែលគេស្លៀកពាក់ឱ្យ ផ្កាទៀនធូបក្នុងដៃ ដែលគេដាក់ឱ្យ និងប្រាក់កាក់មួយ ដែលគេឱ្យបៀមក្នុងមាត់... ។

រីឯបដិសន្ធិវិញ ព្រោះកម្មជាបច្ច័យ ។

**៦៤**. ញញឹមញញែមស្រស់បស់ដើម្បី :

- មិនឱ្យចិត្តតក់ស្លុតចំពោះការពិតនៃធម្មជាតិ
- លួងលោមចិត្តរបស់ខ្លួនឯង
- ដាស់តឿនចិត្តរបស់ខ្លួនឯង
- កម្ចាត់បង់គំនុំ មិនចងពៀរ
- រារាំងការច្រណែន



- ឱ្យអភ័យ
- ចងមេត្រីភាព
- ឱ្យគេសប្បាយចិត្ត ។ល។

ការញញឹម ជាការចុះទុនតិច តែបានកម្រៃច្រើន ។ ថ្ងៃនេះ អ្នកញញឹមហើយ ឬនៅ ?

**៦៥**. ញញឹម ព្រោះស្គាល់សង្ខារលោក
ញញឹម ព្រោះជោគស្ងប់រោគចិត្ត
ញញឹម ម្យ៉ាងនោះព្រោះចរិត
ញញឹម ប្រណីតព្រោះចិត្តជា ។
ញញឹម តស៊ូនឹងឧបសគ្គ
ញញឹម បំបាក់សេនាមារ
ញញឹម ព្យាបាលអស់រោគា
ញញឹម រាប់គ្នាចិត្តមេត្តា ។
ញញឹម ព្រះពុទ្ធ អានន្ទសួរ
ញញឹម គាប់គួរ តាមធម្មតា

ញញឹម  ហ្វឹកហាត់ កាត់ទោសា
ញញឹម  ស្នេហា មិនបាច់ហាត់ ។

**៦៦.** ថែមធម៌ល្អ១ ឱ្យជីវិត
អប់រំគំនិត កាមត្រូវកាត់
ចម្រើនមេត្តា ពៀរត្រូវបាត់
ស្វែងសែងកម្ចាត់ អន្ធិកា ។

ជនខ្វះស្មារតី  ពោលឬធ្វើអ្វី  អប្រិយ៍អាត្មា
ឬជួបគ្រោះថ្នាក់  ដូចខ្វាក់នេត្រា  ដើរតាមមាគ៌ា
ពិតជាធ្លាក់ផ្លូវ ។

ជនអប្បប្រាជ្ញា  ជីវិតមោហា  គិតការមិនត្រូវ
ដូចទាំងខ្វាក់ភ្នែក ទូលវែកដើរទៅ  ទាំងមិនដឹងផ្លូវ
ថាត្រូវទៅណា ។

ព្រោះហេតុដូច្នេះ មិនត្រូវប្រហែស ត្រូវចេះសិក្សា
សេពគប់ឱ្យសម  អប់រំបញ្ញា  ដើរតាមមាគ៌ា
អដ្ឋង្គិកមគ្គ ។



**៦៧.** រវល់  ជជែកឥតខ្លឹមសារ
រវល់  ផឹកស្រាជុំមិត្តភក្តិ
រវល់  ដោះស្រាយឱ្យរាគះ
រវល់  ជាប់ផ្ទាក់នរកលោកីយ៍ ។
រវល់  តែហូបបីបួនដង
រវល់  ដេកផងខ្ជិលធ្វើអ្វី
រវល់  តរៀងរាល់រាត្រី
ធ្វើល្អស្រដីថាអត់ពេល ។
បរិភោគកាមគុណពេញបន្ទុក
ផឹកស្រាស្រណុកដេកទ្រោបទ្រេល
បរទារកម្មដូចអចេលក៍
ធ្វើល្អអត់ពេលសែនស្រណោះ ។
មនុស្សចិត្តអាក្រក់ចេះបរិភោគ
វិជ្ជាក្នុងលោកចេះទាំងអស់
ចេះសព្វការងារល្បីទាំងឈ្មោះ
មិនចេះមួយនោះគឺធ្វើល្អ ។

**៦៨.** -ជីវិតគឺជាអ្វីទៅហ្ន៎ ?

-អ្វីជាទិសដៅដ៏ពិតប្រាកដរបស់ជីវិត ?

-ជីវិតគួរប្រព្រឹត្តទៅយ៉ាងណាទើបល្អ ?

ទាំងនេះគឺជាសំណួរដែលគួរគិត និង គួរឆ្លើយដោយ ខ្លួនឯង ។

**៦៩.** -កើតមកធ្វើអ្វី ?

-ធ្វើការងារហត់នឿយដើម្បីអ្វី ?

-អ្វីដែលចាំបាច់ត្រូវរៀនឱ្យដឹង ?

-ជីវិតជាការតស៊ូ ហើយតស៊ូក្នុងរឿងអ្វី ?

-គួរមានជីវិតរស់នៅដើម្បីនរណា ?

បើបានដឹងត្រឹមត្រូវក្នុងបញ្ហាទាំងអស់នេះ ការធ្វើអត្តឃាតព្រោះសោកសៅ មុខជាមិនមានឡើយ ។ ការបៀតបៀនគ្នាក៏មិនបានកើតឡើងដែរ មានតែពរដ៏ប្រសើរជាគូជីវិតប៉ុណ្ណោះ ។



**៧០.**

| | | |
|---|---|---|
| **ជីវិតនេះ** | **រស់ល្អស្រស់** | **ព្រោះធម្មា** |
| **គួរម្នីម្នា** | **ខំសិក្សា** | **សាងសន្សំ** |
| **ផ្តាច់វេរា** | **លះឥស្សា** | **ការឧត្តម** |
| **ទើបសមរម្យ** | **ជាពុទ្ធបុត្រ** | **ផុតទុក្ខា។** |

-ជីវិតនេះ គួរម្នីម្នា ផ្តាច់វេរា ទើបសមរម្យ

ព្រោះធម្មា សាងសន្សំ ការឧត្តម ផុតទុក្ខា ។

-រស់ល្អស្រស់ ខំសិក្សា លះឥស្សា ជាពុទ្ធបុត្រ ។

-ជាពុទ្ធបុត្រ គួរម្នីម្នា ខំសិក្សា... ។

ចប់

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការខារធម្មទាន

១. ឧបាសក សំរ៉ង វណ្ណ  ២. ឧបាសក យន្ត សួន

៣. ឧបាសក គួង លាងផេង  ៤. ឧបាសក មួង យេន

៥. លោកគ្រូ រស់ សូផាត  ៦. ឧបាសក អ៊ិត ប្រាំង

៧. នាង ជា សុណារី  ៨. នាង ឃុន សូនីម៉ា

៩. ឧបាសិកា ហួនចាន់បូដា  ១០. ឧបាសក វ៉ាន់ ខុនណា

១១. ឧបាសក គុយ សុធន  ១២. ឧបាសក ជឹង វេងអ៊ាវ

១៣. ឧបាសក ជឹម ជំនិត  ១៤. ឧបាសក ហាយ ចំរើន

១៥. ឧបាសិកា ប៊ុត ម៉ាលី  ១៦. ឧបាសិកាហាយ ច័ន្ទធរី

១៧. លោកគ្រូ ជូ ប៊ុនយូ  ១៨. ឧបាសក ង៉ូវ គា

១៩. ឧបាសក ម៉ៅ ផុន



## សព្វទានំ ធម្មទានំ ជិនាតិ

ធម្មទានឈ្នះអស់ទានទាំងពួង ។

# I

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | ពេលផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -04h50 mn<br>-05h00 mn<br>-05h30 mn<br>-12h10 mn<br>-18h00 mn<br>-19h00 mn<br>-20h00 mn<br>-20h30 mn | -FM 98 MHz<br>-FM 99 MHz<br>-FM 96 MHz<br>-FM 96 MHz<br>-FM 95 MHz<br>-AM 918 KHz<br>-FM 98 MHz<br>-FM 96 MHz |
| ក្រុងព្រះសីហនុ | -06h00 mn<br>-13h00 mn<br>-17h30 mn | -FM 92 MHz<br>-FM 92 MHz<br>-FM100.5MHz |
| ខេត្តបាត់ដំបង | -05h30 mn<br>-06h00 mn<br>-18h00 mn<br>-18h30 mn<br>-19h30 mn | -FM103.2MHz<br>-FM 92.7MHz<br>-FM 91 MHz<br>-FM 92.7MHz<br>-FM103.2MHz |

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ។



# II

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | ពេលផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| ក្រុងប៉ៃលិន | -18h00 mn | -FM 90.5 MHz |
| ខេត្តសៀមរាប | -05h00 mn<br>-18h30 mn | -FM 98 MHz<br>-FM 100.5 MHz |
| ខេត្តពោធិ៍សាត់ | -06h00 mn | -FM 98.5 MHz |
| ខេត្តកំពត | -05h00 mn<br>-18h30 mn | -FM 93.25 MHz<br>-FM 103.5 MHz |
| ខេត្តព្រះវិហារ | -18h30 mn | -FM 99 MHz |
| ខេត្តបន្ទាយមានជ័យ | -05h20 mn<br>-17h00 mn | -FM 96.5 MHz |
| ខេត្តស្វាយរៀង | -05h30 mn | -FM103.75MHz |

**សុខោ បុញ្ញស្ស ឧច្ចយោ**

ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ ។

## សៀវភៅដែលរៀបរៀងដោយ

## ✍ ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត_សាវង្ស ✍

១. បារមីភាគទី ២ និងខ្លឹមសារខ្លីៗ

២. ជំនួយសតិភាគទី ១ ដល់ភាគទី ១១

៣. មនុស្សជាមួយនឹងការងារ

៤. សិក្ខាបទមនុស្សល្អ

៥. ពរ ៤ ប្រការ

៦. ព្រះពុទ្ធភាសិត ៤៣ គាថា

៧. ខ្លឹមសារគួរយល់ដឹង

៨. ព្រះពុទ្ធសាសនា

៩. កូនមាសឪពុក

១០. ម៉ែ !!!

១១. វិធីរម្ងាប់សេចក្ដីក្រោធ

១២. សុខចិត្ត និងគុណភាពនៃជីវិត

១៣. មេរៀនជីវិត

១៤. ពាក្យពេចន៍ម៉ែឪ

១៥. បទពិចារណា

១៦. ពន្លឺធម៌ព្រះពុទ្ធ

១៧. បារមីភាគទី ១ និងខ្លឹមសារខ្លីៗ



## កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃទានទាំង ១០ នេះគឺ

១.ឱ្យទានមិនត្រូវសង្ឃឹមផល អ្នកទទួលមិនគួរភ្លេច ។

២.បើមិនធ្វើល្អទេរស់នៅ ១០០ ឆ្នាំក៏ពុំមានប្រយោជន៍ដែរ។

៣.បើឃើញតែពីបានទេ កុំសង្ឃឹមទឹកចិត្តអ្នកដទៃ ។

៤.កុំទុកចិត្តមនុស្សដែលគិតតែពីប្រយោជន៍ខ្លួនឯង ។

៥.មនុស្សត្រូវតែចេះឱ្យទាន បើមិនច្រើនក៏តិចដែរ ។

៦.មនុស្សល្អ រមែងពេញចិត្តជួយឱ្យគេបានសុខ ។

៧.ឱ្យទាន រមែងបានមិត្ត និងកម្ចាត់គំនុំក្នុងចិត្ត ។

៨.ឱ្យទាន ដូចជាការនាំទ្រព្យចេញពីផ្ទះដែលត្រូវភ្លើងឆេះ។

៩.ទានគឺជាស្បៀងក្នុងដំណើរផ្លូវទៅកាន់ព្រះនិព្វាន ។

១០.ចេះឱ្យទានហើយ មិនគួរបៀតបៀនសត្វទេ ។

# ពាក្យប្រារព្ធ

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា :

អ្នកទាំងឡាយចូរឃើញភ័យក្នុងសេចក្តីខ្ជិលច្រអូស ចូរឃើញការប្រារព្ធនូវសេចក្តីព្យាយាមថា ជាផ្លូវនៃសេចក្តីសុខក្សេមក្សាន្ត ហើយចូរប្រារព្ធនូវសេចក្តីព្យាយាមចុះ នេះជាពាក្យទូន្មានប្រៀនប្រដៅ នៃព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ៗ ព្រះអង្គ ។

អ្នកទាំងឡាយចូរឃើញភ័យក្នុងវិវាទ ចូរឃើញការមិនមានវិវាទថា ជាផ្លូវនៃសេចក្តីសុខក្សេមក្សាន្ត ហើយចូរពោលវាចាទន់ភ្លន់ផ្អែមល្ហែម ប្រកបដោយការព្រមព្រៀងគ្នាចុះ នេះជាពាក្យទូន្មានប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ៗ ព្រះអង្គ ។

អ្នកទាំងឡាយចូរឃើញភ័យក្នុងសេចក្តីប្រមាទ ចូរឃើញការមិនប្រមាទថា ជាផ្លូវនៃសេចក្តីសុខក្សេមក្សាន្ត



ហើយចូរចម្រើននូវមគ្គប្រកបដោយអង្គ ៨ ប្រការចុះ នេះជាពាក្យទូន្មានប្រៀនប្រដៅនៃព្រះសម្មាសម្ពុទ្ធ ទាំងឡាយគ្រប់ៗ ព្រះអង្គ ។

អដ្ឋកថាចរិយាបិដក មានការបកស្រាយអំពីបារមីដោយន័យផ្សេងៗ ខ្ញុំព្រះករុណា ខ្ញុំបាទ ដកស្រង់កន្លែងខ្លះកាត់ចេញខ្លះ និងពន្យល់ពាក្យដោយការបញ្ចូលសេចក្តីខ្លះតាមសមគួរ ហើយប្រមូលបានជាកូនសៀវភៅ ភាគទី ១ និងភាគទី ២ នៃធម៌បារមី ព្រមដោយខ្លឹមសារខ្លីៗ ដែលមានអត្ថន័យសម្រាប់គិតពិចារណា ។

សៀវភៅបារមីទាំង ២ ភាគនេះ មានប្រយោជន៍ដល់ពុទ្ធបរិស័ទក្នុងការយល់ដឹងអំពីខ្លឹមសារនៃបារមី បានច្បាស់លាស់ត្រឹមត្រូវ កុំឱ្យយល់ខុសនូវពាក្យថា « បារមី » និង ដើម្បីឱ្យបាននូវសេចក្តីជ្រះថ្លា ច្រើនឡើងៗ ចំពោះគុណព្រះរតនត្រៃ ដែលជារតនៈដ៏មានតម្លៃបំផុត ព្រោះថាព្រះរតនត្រៃកើតមានក្នុងលោកព្រោះបារមីនោះឯង ។

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនាបុណ្យ ដែល

ពុទ្ធបរិស័ទ បានកសាងគម្ពីរព្រះត្រៃបិដកខ្មែរ ដាក់តាមវត្តនានា និងសូមមានពាក្យពោលខ្លះ ដូចនេះថា « បើចង់ឃើញអ្វីដែលល្អ សូមអានព្រះត្រៃបិដកចុះ ឯអ្វីៗផ្សេងៗទៀតនោះ សូមឱ្យព្រមតាមសច្ចៈនៃធម្មជាតិ មិនចាំបាច់តម្រូវតាមចំណង់របស់ខ្លួនឡើយ ប៉ុន្តែយើងត្រូវរៀបចំឱ្យអ្វីៗទាំងនោះ ក្លាយមកជាប្រយោជន៍ក្នុងការបំពេញនូវបារមីគ្រប់យ៉ាងទាំងអស់ » ។

អ្វីៗ ក្នុងលោកទោះជាល្អយ៉ាងណា គេសន្មតថាពិសេសយ៉ាងណា ឬសូម្បីសម្បត្តិទិព្វក៏ដោយ ក៏មិនអាចមកទម្លាយកិលេសឱ្យដូចជាបារមីដែលបានសន្សំដែរ ។

ការបំពេញបារមី ធ្វើឱ្យមានលំនឹងក្នុងចិត្ត មិនញាប់ញ័រនឹងលោកធម៌ទាំង ៨ ដោយយកការបានលាភមកបំពេញទានបារមី យកការអត់លាភមកចម្រើនសេចក្តីសន្តោស យកការបានយសមកបំពេញវីរិយបារមី ទទួលខុសត្រូវក្នុងតួនាទី យកការអត់យសមកបំពេញការមិនកង្វល់ យកពាក្យសរសើរមកបំពេញមេត្តា យកពាក្យនិន្ទា



មកចម្រើនខន្តី យកសុខមកចម្រើននេក្ខម្មៈ និងយកទុក្ខមកចម្រើនឧបេក្ខា បំពេញបារមីចម្រើនវិបស្សនា ។

កាលណា យើងឃើញបារមីកាន់តែមានគុណតម្លៃក្រៃលែងឡើង កាលនោះយើងនឹងលះបង់បាននូវសេចក្តីប្រាថ្នាចំពោះសម្បត្តិក្នុងលោកផ្សេងៗ ទីបំផុតយើងនឹងរួចផុតចាកអំពីចំណងនៃវដ្តសង្សារ ។

សូមពុទ្ធបរិស័ទរីករាយក្នុងការអាន ឬស្តាប់នូវឱវាទរបស់ព្រះសម្មាសម្ពុទ្ធ និងសូមឱ្យបារមីស្ថិតក្នុងដួងហឫទ័យនៃពុទ្ធបរិស័ទអស់កាលជានិច្ច ។

**ដោយបំណងល្អដ៏ក្រៃលែង**

**ប៊ុត សាវង្ស**

**ថ្ងៃ១៥កើត ខែកត្តិក ព.ស.២៥៥០**

## សារបណ្ណ


ឈ្មោះអត្ថបទធម៌ ..... ទំព័រ

**១_ចំណុចបដិបត្តិនៃបារមី** ..................១

_ចំណុចបដិបត្តិនៃទានបារមី ..................១

_ចំណុចបដិបត្តិនៃសីលបារមី ..................១៥

_ចំណុចបដិបត្តិនៃនេក្ខម្មបារមី ..................២៨

_ចំណុចបដិបត្តិនៃបញ្ញាបារមី ..................៣២

_ចំណុចបដិបត្តិនៃវីរិយបារមី ..................៤៣

_សង្ខេបចំណុចបដិបត្តិនៃបារមីទាំងអស់ .........៥២

**២_ការចែកបារមី** ..................៥៥

**៣_គុណធម៌សម្រេចដោយគុណបារមី**..................៥៨

**៤_ឧបាយឱ្យសម្រេច** ..................៦១

**៥_រយៈពេលនៃការសម្រេច** ..................៦៩

**៦_អានិសង្សរបស់បារមី** ..................៧២

**៧_ផលរបស់បារមី** ..................៩២

**៨_ខ្លឹមសារខ្លីៗ** ................១០៣




## មនុស្សប្រសើរជាងសត្វព្រោះគុណធម៌

គ្រប់សត្វមានជីវិត សុទ្ធតែមានចិត្តជាប្រធាន មានចិត្តជាធំ ។ មនុស្សមានវិធីអប់រំចិត្ត តែសត្វតិរច្ឆានមិនមានឡើយ ដូច្នេះជីវិតមនុស្ស និងជីវិតសត្វតិរច្ឆានទើបផ្សេងគ្នា ពោលគឺមនុស្សបានប្រសើរត្រង់មានការចម្រើនផ្លូវចិត្ត ចម្រើនគុណធម៌ អប់រំរឿយៗ ។


**បោះពុម្ពជាធម្មទាន ៥០.០០០ ក្បាល**

**ក្នុងតម្លៃ ១៨.០០០ ដុល្លារ**

**រោងពុម្ពឥន្ទ្រីយ៍មាស**